ទស្សនាវដ្ដី លេខ ១២

# ពុទ្ធិកវិទ្យាល័យ



ទីចាត់ការ វត្តលង្កា សង្កាត់លេខ ៦
ភ្នំពេញ

ចាងហ្វាង. ចណ្ណាធិការ.

ក 135
ក 135 ខ

I.K - 13
1956 - 12

គ (135)

# មាតិការឿង


| | | |
|---|---|---|
| បណ្ណាធិការ | វិចារណកថា | ទំព័រទី ១ |
| ភិក្ខុ អាំ-សួន (ហៅ ហម) | សាសនាជេន នឹងពុទ្ធសាសនា | ,, ៤ |
| ព្រះពុទ្ធវង្ស កៅ-ស៊ឹម | បុរាណនិវេសន៍ | ,, ១៣ |
| លោក តែ-ជុន | ជ័យព្រាជ្ញ (ត) | ,, ១៩ |
| ព្រះគ្រូបវរត្តិមវាលី អ៊ូ-ប៉េវ | ជនក្លាយបណ្ឌិត | ,, ២៥ |
| | ប្រអប់សំបុត្រ | ,, ៣០ |
| | ការប្រែប្រួល | ,, ៣៥ |
| | សេចក្ដីថ្លែងអំពីការអប់រំសីលធម៌ | ,, ៣៧ |
| | ពាក្យកំណាព្យភាពខ្មែរសម័យ | ,, ៤០ |


## ដំឡៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ ខែ | ១ ឆ្នាំ | ១ក្បាល | ៦ ខែ | ១ ឆ្នាំ | ១ក្បាល |
| ៥០៖០០ | ១០០៖០០ | ១០៖០០ | ៦០៖០០ | ១២០៖០០ | ១៣៖០០ |

## អ្នកទទួលឲ្យជាវ

សូមផ្ញើចំពោះទៅលោក ម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

ADRESSE: Monsieur Mao-Mey Ministère de L'Intérieur P.Penh

# វិចារណកថា

## គួរគោរពព្រះពុទ្ធសាសនាដែរឬ ?

គ្រប់តែប្រជាជាតិក្នុងលោកគេតែងមានសាសនាប្រចាំរដ្ឋរបស់គេជានិច្ច ហើយសាសនានេះហើយដែលសម្រាប់បំពត់ចិត្តគំនិតប្រជាជនឲ្យជឿស៊ប់ក្នុងជំនឿមួយ ដែលពលរដ្ឋរបស់គេតែងនិយម ។

ចុះមនុស្សបែបណាដែលបង្កបង្កើតជំនឿនេះឡើង ដោយមានសារៈបែបណាទៅ? បានជាមនុស្សមានចំនួនច្រើនគោរពកោតខ្លាចអ្វីខ្លាំងម្ល៉េះ ? តើគុណធម៌នឹងឧត្តមគតិរបស់មនុស្សនោះបែបណាទៅវិញ ? មិនតែប៉ុណ្ណោះកិត្តិសព្ទក៏នៅរស់រវើករាប់ពាន់ម៉ឺនឆ្នាំ ដែលពិភពលោកគេនៅនិយមជឿកាន់តាម គោរពថ្វាយបង្គំជានិច្ច ។ គេតែងដឹងច្បាស់ថា ក្នុងសង្គមនៃប្រជាជាតិមួយ យ៉ាងហោចណាស់ក៏មានសាសនាមួយសម្រាប់ប្រជាជនគោរពរាប់អានដែរ ហើយប្រជាជាតិជាមួយគ្នាដែលនោះឯង គង់និយមយករបបប្រតិបត្តិសាសនាក្រៅពីប្រជាជាតិខ្លួនមកគោរពខ្លះទៀត ដែលថ្ងៃក្រោយទៅក៏ក្លាយជាជំនឿប្រឆាំងគ្នាច្រើនអន្លើ មានជួនកាលក៏កើតទៅជាសង្គ្រាមសាសនារវាងជាតិនឹងជាតិទៀត ។

បើដូចនេះ យើងអាចសន្និដ្ឋានថាកំឡាំងសាសនាជាឥទ្ធិពលមួយសម្រាប់ដឹកនាំមនុស្សលោកឲ្យដើរទៅតាមបំណងតែមួយនៃអ្នកប្រាជ្ញ ដែលបានកសាងសាសនាឡើង ៗ តែយើងអាចសួរបានដូចម្ដេចទៅវិញ លើគោលបំណងនៃអ្នកបង្កើតសាសនាមួយ ៗ ? ថាអ្នកបង្កើតសាសនានេះ ក៏មិនខុសគ្នាពីអ្នកប្រាជ្ញវិទ្យាសាស្ត្រ

បង្កើតលទ្ធិដែរ ព្រោះកម្លាំងលទ្ធិក៏គង់មានជីវិតរស់នៅបានយូរ ហើយមានឥទ្ធិពលប្រាកដនៅលើលោកទាំងមូលបានដែរ ហើយរបបលទ្ធិនេះ មានការរំលោភលើទឹកចិត្តនៃប្រជាជនច្រើនជាងរបបសាសនា ។ ហេតុនោះហើយបានជាក្នុងជុំលោកនេះសង្គ្រាមច្រើនកើតមកតែពីរបបផ្សាយលទ្ធិប៉ុណ្ណោះ ព្រោះថាប្រទេសណាបានបង្កើតលទ្ធិណាដែលប្រជាជនក្នុងលោកគោរពរាប់អានច្រើន កិត្តិយសប្រទេសនោះមួយអន្លើដោយប្រជាជាតិ គេក៏គង់មានសិទ្ធិលើប្រទេសដទៃខ្លះ ដែលប្រតិបត្តិតាមរបបលទ្ធិរបស់គេដែរ ។

តាមពិតយើងហ៊ានចោទដោយបំពោះថា ទាំងរបបលទ្ធិ ទាំងរបបសាសនាក៏សុទ្ធជាដំណើររើរបំបាត់សិទ្ធិសេរីភាពរបស់មនុស្សលោកទាំងអស់ ។ ព្រោះថាសិទ្ធិសេរី-ភាពរបស់មនុស្សដែលឲ្យឈ្មោះថាមានគ្រប់គ្រាន់ក្នុងខ្លួនបាន លុះត្រាតែជននោះមិនទំពឹងលើផ្នត់គំនិតនៃអ្នកកាន់លទ្ធិនិងសាសនា តែបើយើងបេះតែបណ្ដោយបែបនេះរហូតទៅ មនុស្សលោកគ្រប់ប្រភេទគ្រប់ជាន់គ្រប់ថ្នាក់ រស់នៅគ្រាន់តែជាជណ្ដើរសាសនានិងលទ្ធិប៉ុណ្ណោះ ។ សូមយកឧទាហរណ៍ដោយខ្លីមកលាតត្រដាងឲ្យច្បាស់ថា តើមនុស្សលោកដែលធ្លាប់អួតសរសើរនិងធ្វើបុណ្យរំលឹកពីរឿងសិទ្ធិមនុស្សនោះ តើសិទ្ធិនឹងមានមកពិតតាមការប្រកាសដោយយោបល់នោះទេ ថាលទ្ធិប្រជាធិបតេយ្យដែលជារបបមួយធ្លាប់មានក្នុងប្រទេសយើងមិនទាន់ជាយូរប៉ុន្មាន តើរបបនេះជាដំណែលរបស់ប្រជាជាតិខ្មែរឬ? លទ្ធិរួមសម្លាប់ដែលបេះតែជ្រៀតជ្រែកក្នុងបេះដូងរបស់ប្រជាជាតិខ្មែរសព្វថ្ងៃ តើជាកេរ្ដិ៍ដំណែលរបស់ប្រជាជាតិខ្មែរដែរឬទេ? និងរបបរាជាធិប-តេយ្យ ដែលជារបបមួយផ្សេងទៀតសម្រាប់ថ្វឹងភេទមនុស្សឲ្យអ្នកផងមើលឃើញថា

មានជំនឿខុសពីមនុស្សសាមញ្ញ ដែលអ្នកប្រាជ្ញសាសនាបានពោលថាជាមនុស្សអកិ-នហារកសាង់ច្រើន ។ ចំពោះសាសនាក៏គេនៅមានប្រកាន់ជំនឿយ៉ាងប្លែក ៗ ដែលគួរតែយើងយកមកចោទដែរ ! ព្រះពុទ្ធសាសនាក៏ជារបបមួយរបស់ជនជាតិក្លិងឯណោះ ម្ដេចក៏ប្រជាជាតិខ្មែរទំលាក់ជំនឿខ្លួនលើព្រះពុទ្ធសាសនា, ព្រាហ្មណ៍, យេស៊ូ, មហាម័ត ... ទៅវិញ ។ ហើយនាំឲ្យប្រជាជាតិយើង ភ្លេចនឹកដល់ករណីរបស់ខ្លួនដែលត្រូវកសាងប្រទេសឲ្យដើរទៅរកអារ្យធម៌ទៅអនាគត ដែលសព្វថ្ងៃកំពុងជួបប្រទះលើការវិបត្តិយ៉ាងច្រើនឥតគណនា ។

ជំនឿទាំងឡាយរបស់លទ្ធិ សាសនាក្ដី ក៏គ្រាន់តែជាទ្រឹស្ដីសម្រាប់បង្វឹកមនុស្សឲ្យយល់នឹងប្រកាន់ខុស ហើយតែងតុះតិះដៀលមនុស្សផងគ្នាឲ្យខ្វះសេចក្ដីក្លាហានដើម្បីធ្វើការឲ្យជាតិទាំងស្រុង ។ លោក-អ្នកអានជាទីគោរពត្រូវពិចារណាមើល លទ្ធិនឹងសាសនានេះ គ្រាន់តែជាអំណាចសង្កត់អ្នកតូចតាចប៉ុណ្ណោះទេ ដែលគេសម្រាប់ប្រើខ្លួនបំពត់កាយឲ្យក្លាយទៅជាមនុស្សរសនៅដោយឯកឯងហើយគ្មានសង្ឃឹម ។

តាមគិតជំនឿទាំងអស់ក្នុងលោកមុននឹងយើងផ្អែកខ្លួនទៅលើអ្វីៗក៏ដោយ ក៏ត្រូវកុំយកលំអានណាដែលមិនមែនជាឧត្ដមប្រយោជន៍របស់ប្រទេសមកដើម្បីជីវិតកសាងរបស់ប្រទេសយើងឡើយ ។ ហើយត្រូវយើងបញ្ជាក់ទៅតាមឡាក់គោលទាំងឡាយដែលអាចឲ្យមនុស្សម្នាក់ ៗ មើលគ្នាឃើញច្បាស់ហើយទុកឱកាសនឹងជួយមនុស្សផងគ្នាឲ្យរស់នៅធ្វើការស្រួល អាចបំរើប្រទេសជាតិបានទៅអនាគតដែលយើងម្នាក់ ៗ មិនធ្វើចិត្តគំនិតឲ្យលង់គ្រាន់នឹងបំផ្លាញខ្មែរដែលមានឧត្ដមគតិដើម្បីប្រទេសជាតិឡើយ ។

យើងគួរគោរពព្រះពុទ្ធសាសនាឬ ?

លទ្ធិមនុស្សក្នុងលោក ?



## សាសនាជេន និងពុទ្ធសាសនា (តនិងចប់)

### ទីកន្លែងដែលមហាវីរៈ ធ្លាប់នៅអាស្រ័យ

រវាង ៣០ ឆ្នាំ តាំងពីបានត្រាស់មកដល់ពេលនិព្វាន មហាវីរៈ (និគណ្ឋនាដបុត្ត) បាននៅចាំវស្សាជាច្រើនកន្លែងដូចតទៅ:

៤ វស្សាក្នុងក្រុងវេសាលី និងពាណិជ្ជគ្រាម,

១៤ វស្សាក្នុងក្រុងរាជគ្រឹះ និងនាលន្ទា,

៦ វស្សាក្នុងក្រុងមិថិលា,

២ វស្សាក្នុងក្រុងភទ្ទិកា,

១ វស្សាក្នុងស្រុកអាលភិកា,

១ វស្សាក្នុង បណីតភូមិ,

១ វស្សាក្នុងក្រុងសាវត្ថី,

១ វស្សាក្នុងក្រុងបាវ៉ា ដែលជាវស្សាក្រោយបំផុត ។

## មហាវីរៈនិព្វាន

នៅថ្ងៃ ១៥ រោចខែកត្តិក ក្នុងលេខាធិការមន្ទីរ នៃព្រះបាទហត្ថិបាលរាជ ក្រុងបាវ៉ា មហាវីរៈបានដកបង្ហើយនូវអស្សាសៈបស្សាសៈ ជាអវសាន ប្រានចេញនូវបំណងគឺ ជាតិ ជរាព្យាធិ មរណៈ ប្រាសចេញចាកលោក ចូលកាន់និព្វាន ។

ក្នុងគល្បសូត្រ គេបានពណ៌នាយ៉ាងវែងទៅទៀតថា មុនចូលកាន់និព្វាន មហាវីរៈ បានទេសនាដល់ពួកបរិស័ទ មានពួកស្តេចមល្លៈ និងលិច្ឆវីជាដើម អស់ ៦ យប់ ៦ ថ្ងៃពុំមានឈប់, លុះដល់ថ្ងៃទី ៧ បានដឹងថាអវសាននៃជីវិតចូលមជិតណាស់ហើយ ក៏អង្គុយពែនភ្នែនប្របាក់ស្រេះ ដៃប្របាក់ស្រេះគ្នាដាក់លើភ្នែន (ដែលហៅថា សម្បូយិង្កាស័ន) ហើយក៏ផ្ចង់ភ្នែក ចូលកាន់និព្វាន នៅវេលាបច្ចូសសម័យនៃថ្ងៃនោះឯង ។

មហាវីរៈ និព្វានក្នុងអាយុកាល ៧២ ឆ្នាំ. មុន គ. ស. ៥២៧ ឆ្នាំ ។

## ការបែកចាកគ្នាជាពីរនិកាយ ក្នុងផ្ទៃសាសនាជេន,

សព្វថ្ងៃគេឃើញមានអ្នកបួសសាសនាជេន ពីរពួកផ្សេងគ្នាគឺៈ ពួកមួយប្រព្រឹត្តអាក្រាត, ពួកមួយទៀតស្លៀកដណ្តប់សំពត់ព័ណ៌ស ។ ពួកអាក្រាត គេហៅថា «ទិគម្ពរនិកាយ», ពួកស្លៀកដណ្តប់សំពត់ព័ណ៌ស ហៅថា "សេតម្ពរនិកាយ" ។

ដំណើរសាសនាជេន អំពីការបែកបាក់គ្នាជាពីរនិកាយ ក៏ស្រដៀងគ្នានឹងដំណើរ
ពុទ្ធសាសនាដែរ ។ ពុទ្ធសាសនា គេច្រើនសន្និដ្ឋានដោយសមហេតុសមផលថា
មានការបែកគ្នាយ៉ាងធំជាពីរនិកាយ គឺថេរវាទនឹងអាចារ្យវាទ ឬហីនយាននឹងមហាយាន
តាំងពីពេលលើកសង្គាយនាទី២ក្រោយព្រះពុទ្ធបរិនិព្វាន១០០ឆ្នាំឬជាងបន្តិចបន្តួច, ដោយ
ពេលនោះតាមគម្ពីរទីបវង្ស មានពណ៌នាថា កាលដែលព្រះអរហន្តទាំងឡាយមានព្រះទេវ
តត្ថេរជាប្រមុខ បានបដិសេធនូវវត្ថុ១០ប្រការដែលពួកវជ្ជីបុត្តកភិក្ខុសំដែងឡើង ហើយ
ប្រជុំសង្ឃជាអរហន្តលើកសង្គាយនាទី២, ឯពួកវជ្ជីបុត្តកៈ ពុំព្រមចុះចូលនឹងព្រះអរហន្ត
ទាំងនោះទេ ថែមទាំងបរិស័ទរបស់ខ្លួនធ្វើសង្គាយនាមួយផ្សេងដោយឡែកទៀត ឲ្យ
ឈ្មោះថាមហាសង្គីតិ ។ ក្នុងពេលនោះពួកវជ្ជីបុត្តកភិក្ខុ បានប្រៀនប្រែផ្លាស់ប្តូរ-កែ
ប្រែធម៌វិន័យរបស់ព្រះសម្ពុទ្ធ ជាច្រើនអន្លើឲ្យស្របតាមមតិខ្លួន ។ ឯសាសនាជេនក៏
ដូច្នោះដែរ គឺមានបែកគ្នាជាពីរនិកាយធំ ៗ គឺ១-ទិគម្ពរនិកាយ (ពួកស្លៀកដណ្ដប់
មេឃគឺអាក្រាត) ពួកនេះកាន់តាមគ្រូដើមគឺមហាវីរៈ ឬនិគណ្ឋនាដបុត្ត, ២-ស្វេតាម្ពរនិ-
កាយឬសេតម្ពរនិកាយ (ពួកស្លៀកដណ្ដប់ពណ៌ស) ពួកនេះបានលះបង់បោលការប្រព្រឹត្ត
អាក្រាតកាយ នឹងបន្ធូរបន្ថយច្បាប់វិន័យដើមជាច្រើនអន្លើ ។

មានរឿងដំណាលថា កាលកន្លងសតវត្សទី២ក្រោយមហាវីរៈនិព្វាន គឺក្នុងរជ្ជកាល
នៃព្រះបាទចន្ទ្រគុប្ត ដែនមគធៈ(រដ្ឋពិហារសព្វថ្ងៃ) មានកើតទុរភិក្សអត់បាយប្រមាណ១២
ឆ្នាំ ។ ពេលនោះភទ្របាហុ ជាថេរៈពហុស្សូត ហើយជាប្រធាននៃលោកសង្ឃជេន
ទាំងអស់ ។ ដោយការទុរភិក្សនោះ ភទ្របាហុបាននាំសិស្សជំនិតខ្លះរត់ទៅនៅអា-
ស្រ័យឯក្រុងកណាដ, ឥណ្ឌាប៉ែកខាងត្បូង ។ ពេលនោះគេតាំងថេរៈស្ថូលភទ្រៈ

ដែលមានការចេះដឹងគួរសមហើយចាស់ជាងគេ ឲ្យជាប្រធានសង្ឃដែលស្ថិតនៅក្នុងដែនមគធៈ ។ ដោយការលំបាកលំបិនខ្លាំងពេកស្ថូលភទ្រៈបានឲ្យបន្ធូរបន្ថយការប្រតិបត្តិខ្លះ ៗ ជាលំដាប់ ៗ តាមប្រវត្តិសាសនាជៃន ថាពេលនោះស្ថូលភទ្រៈបានប្រជុំធ្វើសង្គាយនាក្នុងក្រុងបាតលិបុត្ត កែប្រែធម៌វិន័យឲ្យស្របទៅតាមមតិខ្លួនហើយនាំគ្នាស្លៀកដណ្ដប់សំពត់ពណ៌ស, គោរសក់ដោយកាំបិត (មិនដក)តាំងពីពេលនោះមក ។

លុះពួកភទ្រៈពាហុត្រឡប់មកពីតំណៀងខាងត្បូងវិញ ក៏មានការជំទាស់គ្នាយ៉ាងធំ ពុំព្រមចុះចូលយល់ស្របតាមគ្នា ។ ពួកភទ្រៈពាហុនៅតែប្រព្រឹត្តអាក្រាត ដកសក់ កាន់ធម៌វិន័យតាមបែបដើម ។ ពួកនេះបានបដិសេធដាច់ខាត នូវមតិដែលពួកស្ថូលភទ្រសំដែងឡើង ។ ប៉ុន្តែពេលនោះពួកភទ្រពាហុ ក៏ពុំមានលើកសង្គាយនាផ្ទៀងផ្ទាត់ធម៌វិន័យអ្វីឡើយ ។

តាំងពីពេលនោះមកពួកភទ្រពាហុ គេហៅថា “ទិគម្ពរនិកាយ„ ពួកស្ថូលភទ្រៈហៅថា „សេតម្ពរនិកាយ„ ។

ក្រោយមកក្នុងសតវត្សទី ១០ ក្រោយមហាវីរៈនិព្វាន (ប្រហែលខាងចុងសតវត្សទាំង៥ ឬ ខាងដើមសតវត្សទី៦នៃគ.ស.) ពួកសេតម្ពរនិកាយ បានលើកសង្គាយនាម្ដងទៀតក្នុងក្រុងវល្លភី ដែនគុជរ័ត (Gujarat) រៀបរៀងសរសេរធម៌វិន័យជាគម្ពីរ ។

ឯពួកទិគម្ពរនិកាយ ក៏ពុំឃើញលើកសង្គាយនាអ្វីទេ, តែថាពេលក្រោយពីនោះមក មានសរសេរចារធម៌វិន័យជាគម្ពីរដែរ ។

ព្រោះហេតុនោះ សព្វថ្ងៃនេះ គេឃើញមានគម្ពីរសាសនាជៃនជាពីរបែប របស់និកាយទាំងពីរ ដែលមានពណ៌នាខុសគ្នាជាច្រើនអន្លើ ។

## លទ្ធិជេននឹងពុទ្ធ

ពាក្យប្រៀនប្រដៅរបស់សាសនាជេនដែលមានពណ៌នាក្នុងគម្ពីរនោះ ៗ គេឃើញមានដូចគ្នានឹងព្រះពុទ្ធសាសនាជាច្រើនអន្លើ ៗ បណ្ឌិតឈ្មោះ ម៉ូរិស វិន្ទើរនិត្ស (Maurice Winternitz) បានសន្និដ្ឋានថា «គម្ពីរសាសនាជេន ដែលសរសេរក្រោយគម្ពីរពុទ្ធសាសនាបានចម្លងប្តិតតាមលទ្ធិពុទ្ធសាសនាជាច្រើនក្រៃលែង» ៗ

លទ្ធិជេន សំដែងប្រឆាំងនឹងសាសនាព្រាហ្មណ៍ជាច្រើនអន្លើដូចជាពុទ្ធសាសនាដែរ, ដូចយ៉ាងការប្រកាន់ ជាតិ គោត្ត ត្រកូល វណ្ណៈខ្ពស់ទាប, ការប្រព្រឹត្តងូតទឹកលាងបាប, ការដុតភ្លើងបូជាយញ្ញ, សរសើរកាមគុណជាដើមដែលពួកព្រាហ្មណ៍ប្រកាន់ជឿថាជាវត្ថុពិសេសបរិសុទ្ធ ៗ មានសេចក្តីមួយកន្លែងដែលមានលំនាំដូចពុទ្ធសាសនាហើយគួរចាប់ចិត្តថា :

«ប្រសិនបើបារមីធម៌ណាមួយ អាចសម្រេចបានដោយការងូតទឹកត្រជាក់ក្នុងស្ទឹងគង្គា ឬ ទឹកដែលបង្ហូរចុះពីសិវលិង្គ នឹងយោនីនាងទេវម្ចាស់នោះ, ពួកហ្វូងត្រីអណ្តើក ពស់ជាដើម គប្បីសម្រេចបារមីធម៌ជាន់ខ្ពស់បំផុត» ៗ

«ប្រសិនបើទឹកអាចលាងកំចាត់បាបបាន, ពេលដែលលាងបាបនោះ, បុណ្យក៏ត្រូវខ្ចាត់ចេញទៅអស់ដូចគ្នា» ៗ «ពួកព្រាហ្មណ៍បានជឿមាំថា ញាណនឹងបារមីធម៌គ្រប់យ៉ាងអាចសម្រេចបានដោយការដុតភ្លើងបូជា, បើពិតដូច្នោះមែន, ពួកជាងដែកជាងមាសជាដើម ដែលសឹងដុតភ្លើងជានិច្ច គប្បីបានសម្រេចញាណនឹងបារមីធម៌យ៉ាងខ្ពង់ខ្ពស់បំផុត» ប៉ុណ្ណេះជាដើម ៗ

ធម៌ប្រចាំខ្លួនរបស់ពួកជេនគឺអហឹសា (ការមិនបៀតបៀន) ៗ «អហឹសា

បរមោ ធម្មោ = ការមិនបៀតបៀនជាធម៌ដ៏ប្រសើរឧត្តម „ នេះជាឱវាទរបស់មហាវីរៈ ។ ព្រោះហេតុនោះ ពួកជេនិកបព្វជិតតែងមានអម្បោសស្ទាបកាន់ជាប់នៅដៃគ្រប់ ៗ គ្នា , ពេលដើរទៅណាយកអម្បោសគ្រវាសពីមុខ ព្រោះខ្លាចជាន់សត្វល្អិត ។ ធម៌នេះព្រះពុទ្ធជាម្ចាស់ក៏បានត្រាស់សំដែងជាអនេកប្បរិយាយឲ្យពួកពុទ្ធបរិស័ទប្រព្រឹត្តរក្សាឲ្យជាប់លាប់ ។ មិនតែប៉ុណ្ណោះទ្រង់សំដែងពិធីអប់រំបំរើនធម៌នោះឲ្យរឹតតែស្អាតផូរផង់ថែមទៀត, ដូចយ៉ាងមេត្តាភាវនាជាដើម ។

## សច្ចធម៌

តាមដែលឃើញក្នុងអាគតស្ថាននោះ ៗ , មហាវីរៈបានយល់នូវសច្ចធម៌ ៣ ខាងដើម ស្របជៀងនឹងព្រះពុទ្ធជាម្ចាស់ដែរ, គឺយល់ថា : ជាតិ ជរា ព្យាធិ មរណៈជាដើមចាត់ជាកងទុក្ខ ( ទុក្ខសច្ច ); កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ចាត់ជាហេតុបណ្តាលឲ្យកើតទុក្ខ ( ទុក្ខសមុទយសច្ច ): និព្វានចាត់ជាទីរលត់ទុក្ខ ( ទុក្ខនិរោធសច្ច ); ប៉ុន្តែសច្ចទី ៤ គឺមគ្គសច្ច = ឧបាយជាគ្រឿងប្រតិបត្តិដើម្បីរំលត់ទុក្ខដល់នូវព្រះនិព្វាន មហាវីរៈយល់ផ្ទុយនឹងព្រះពុទ្ធស្រឡះ ។ ព្រះពុទ្ធទ្រង់សំដែងថា មជ្ឈិមាបដិបទា ការប្រតិបត្តិជាកណ្តាល ពុំធូរពេកពុំតឹងពេក បានដល់អដ្ឋមគ្គទាំង ៨ ប្រការជាឧបាយឲ្យបានដល់ព្រះនិព្វានជាទីរលត់ទុក្ខ, ចំណែកមហាវីរៈសំដែងថា អត្តកិលមថានុយោគ គឺការប្រព្រឹត្តខ្លួនឲ្យលំបាក ធ្វើពង់កាយឲ្យទ្រុឌទ្រោមថោមថយ ជាឧបាយទៅកាន់ព្រះនិព្វានជាទីរលត់ទុក្ខ ។ ព្រោះហេតុនោះ បានជាមហាវីរៈប្រព្រឹត្តធ្វើខ្លួនឲ្យលំបាកក្រៃលែងដូចបានពណ៌នាមកខាងដើមហើយ ។

ព្រះពុទ្ធជាម្ចាស់កាលដំបូងក៏ទ្រង់ប្រព្រឹត្តអត្តកិលមថានុយោគដែរ គឺទ្រង់ធ្វើទុក្ករកិរិយា អត់អាហារស្គាំងស្គម ដួលដេកលើប្រឋពីពុំបានសម្រេចធម៌អ្វីសោះ អស់រយៈ៦ឆ្នាំ, ដល់ទីបំផុតទ្រង់ឃើញថាការប្រព្រឹត្តបែបនោះ នាំឲ្យលំបាកខ្លួនឥតប្រយោជន៍ បើទុកណាជានឹងបានសម្រេចក៏យូរណាស់ ទើបទ្រង់លះបង់ចោលចេញ ប្រព្រឹត្តបដិបទាជាកណ្ដាលវិញ មិនយូរប៉ុន្មានក៏បានសម្រេចតាមបំណងមែន ។ ព្រោះហេតុនោះកាលទ្រង់សំដែងធម្មចក្កប្បវត្តនសូត្រប្រោសបញ្ចវគ្គិយភិក្ខុទ្រង់ប្រកាសឲ្យលះបង់ធម៌ពីរប្រការដែលស្រណុកពេកនឹងលំបាកពេក គឺកាមសុខល្លិកានុយោគ ការប្រកបខ្លួនក្នុងកាមសុខ នឹងអត្តកិលមថានុយោគ ការធ្វើខ្លួនឲ្យលំបាក, ហើយឲ្យប្រតិបត្តិធម៌ជាកណ្ដាលគឺមជ្ឈិមាបដិបទា ឲ្យទៀងទាត់ត្រឹមត្រូវ នឹងដល់ព្រះនិព្វានឆាប់ ។

ខាងចុងនេះសំខាន់ជាទីបំផុត គួរពិចារណាឲ្យម៉ត់ចត់ ។ អ្នកក្រខ្សត់ឃើញអ្នកដទៃមានទ្រព្យសម្បត្តិច្រើន មានសេចក្ដីសុខស្រួល មានផ្ទះថ្មនៅ មានឡានជិះតែងដឹងច្បាស់ក្នុងចិត្តថា ការទ័លក្រជាទុក្ខ, ទ្រព្យសម្បត្តិធ្វើឲ្យបានសុខស្រួលក្នុងបច្ចុប្បន្ន. តែបើពុំមានឧបាយល្អ ពុំឈ្លាសវៃ ក្នុងការស្វែងរកទ្រព្យសម្បត្តិនោះទេ ទោះខំប្រឹងយ៉ាងណាក៏នៅតែក្រដដែល ឬបើនឹងបានសម្រេច ក៏យូរក្រៃលែង ។

បុគ្គលគ្រប់រូបតែងដឹងថាមាសជារបស់មានតម្លៃពិត, តែបើគ្មានវិជ្ជានឹងច្នៃមាសនោះទេ គិតតែយកញញួរដំផ្ចាប់នឹងដែកទទាប់យ៉ាងអស់ទំហឹង តើកាលណាអើយមាសនឹងបានទៅជាគ្រឿងអលង្ការដ៏វិចិត្រ ? ។ គេតែងដឹងគ្រប់ ៗ គ្នាថានគរវត្តជាករនែងមួយប្រកបដោយទស្សនីយភាពជាទីគាប់ចិត្ត គួរចង់ទៅទស្សនាដោយផ្ទាល់ខ្លួន តែបើពុំមានឧបាយគឺប្រាក់សម្រាប់ជិះរថយន្តទៅទេបែរជាធ្វើដំណើរដោយជើងទទេទៅវិញតើ

ត្រូវលំបាកខ្លួនយ៉ាងណា ? កាលណាទើបបានទៅដល់ ? ។ រឿងនេះមានឧបមាយ៉ាងណា ? ការរកផ្លូវប្រតិបត្តិដើម្បីបានសម្រេចនូវគោលបំណងដ៏ខ្ពង់ខ្ពស់ក៏អាស្រ័យការឈ្លាសវៃប៉ិនប្រសប់យ៉ាងនោះដែរ ។ មហាវីរៈប្រឹងធ្វើទុក្ករកិរិយាគឺអត្តកិលមថា-យោគ អស់ ១២ ឆ្នាំទើបបានសម្រេចញាណជាន់ខ្ពស់របស់ខ្លួន, ព្រះពុទ្ធទ្រង់បានប្រព្រឹត្តទុក្ករៈកិរិយាអស់៦វស្សាដែរ ពុំបានសម្រេចអ្វីសោះ លុះទ្រង់ត្រឡប់ប្រព្រឹត្តតាមមជ្ឈិមាបដិបទាវិញ តើទ្រង់ប្រព្រឹត្តអស់កាលប៉ុន្មានឆ្នាំប៉ុន្មានខែ ? ។ បើទុកជាប្រវត្តិមិនបានប្រាប់ថាព្រះអង្គប្រព្រឹត្តមជ្ឈិមាបដិបទាប៉ុណ្ណោះថ្ងៃប៉ុណ្ណោះថ្ងៃទើបបានសម្រេចពោធិញាណនោះក៏ពិតមែន, តែយើងអាចស្មានបានថាមិនយូរជាងមួយខែទេ ។ បើតាមប្រវត្តិសាសនាជេន, សាវករបស់មហាវីរមានប្រមាណតិចណាស់ ដែលបានសម្រេចធម៌ជាន់ខ្ពស់ដូចមហាវីរៈ ។ ព្រោះហេតុអ្វី ? ព្រោះវិធីប្រតិបត្តិលំបាកខ្លាំងពេកពុំមានអ្នកណាធ្វើបានតឹងរ៉ឹងដូចជាមហាវីរៈ ។ ចំណែកសាវករបស់ព្រះសម្ពុទ្ធជាម្ចាស់វិញមានសម្រេចធម៌ជាន់ខ្ពស់ច្រើនក្រៃពេកពុំអាចរាប់បាន, សូម្បីព្រះពុទ្ធបរិនិព្វានដប់ពាន់ឆ្នាំទៅហើយ ក៏គង់នៅមានព្រះអរហន្តជាច្រើនអង្គ ។ ព្រោះហេតុអ្វី ?ព្រោះមានមគ្គជាគ្រឿងប្រតិបត្តិ មិនតឹងតែងពេកល្មមឲ្យសាវកប្រព្រឹត្តតាមបាន ។

រឿងនេះ សាឲ្យឃើញថា ព្រះពុទ្ធជាម្ចាស់ទ្រង់មានសេចក្ដីឈ្លាសវៃជាទីបំផុតក្នុងការរកផ្លូវប្រតិបត្តិ ។

### អំពីសព្វញ្ញុតញ្ញាណ មហាវីរៈ និងព្រះពុទ្ធ

ពួកនិគណ្ឋសាវក បានជឿជាក់ហើយពោលថា “មហាវីរៈ ជាសព្វញ្ញូ–ត្រាស់ដឹងសព្វគ្រប់គ្មានចន្លោះត្រង់ណា„ ដោយគេលើកយកកេវលញ្ញាណរបស់មហាវីរៈជា

គ្រឿងអាង ។ គេបន្ថែមទៀតថា ញាណរបស់មហាវីរៈ ដូចជាផ្ទៃកញ្ចក់ធ្លុះមួយ, វត្ថុណាមួយដែលស្ថិតនៅពីមុខកញ្ចក់តែងប្រាកដក្នុងផ្ទៃកញ្ចក់យ៉ាងណា, វត្ថុឬអារម្មណ៍ណាមួយ ជាអតីតក្តី អនាគតក្តី បច្ចុប្បន្នក្តី ឆ្ងាយឬជិត ល្អិតឬគ្រោតគ្រាតក្តី តែងប្រាកដដល់បញ្ញាចក្ខុរបស់ មហាវីរៈ យ៉ាងនោះ ។ ទោះមហាវីរៈ ដេកលក់ក្តី ក្រោកដើរក្តីឈរក្តី អង្គុយក្តី តែងមានសព្វញ្ញុតញ្ញាណស្ថិតនៅស្មើជានិច្ចតាមធម្មតា ។ មហាវីរៈ អាចបញ្ញត្តវត្ថុហេតុក្នុងកាលទាំងបីបាន គឺថាហេតុក្នុងកាលទាំងបីមហាវីរៈ បានគិតទុកជាស្រេចតាំងពីដំបូង "បើគេសួរយ៉ាងនេះ ត្រូវឆ្លើយដូច្នេះ, បើគេសួរយ៉ាងនោះ ត្រូវឆ្លើយដូច្នោះ" ជាដើម ។

យើងពុទ្ធមាមកៈ កាលបើបានឮដូច្នោះ ពុំគួរនឹងបដិសេធពាក្យគេថា គេពោលពុំពិតនោះទេ, ព្រោះថាបើយើងនិយាយថាមហាវីរៈ ពុំមែនជាសព្វញ្ញូ, គេក៏នឹងតបពាក្យដដែលមកយើងវិញថា ព្រះសមណគោតមក៏ពុំមែនជាសព្វញ្ញូដែរ ។

បើដូច្នេះ សព្វញ្ញុតញ្ញាណរបស់ព្រះសមណគោតមបរមគ្រូនៃយើងយ៉ាងណាដែរ? មានសេចក្តីពិសេសប្លែកពីគេដូចម្តេចខ្លះ?

"ភគវតោ សព្វញ្ញុតា អាវជ្ជនប្បដិពទ្ធា" "សព្វញ្ញុតញ្ញាណរបស់ព្រះមានព្រះភាគ តែងជាប់ទាក់ទងដោយអាវជ្ជនៈ គឺការពិចារណារំពឹងមើល" ។

សេចក្តីថា ក្នុងទីណា ពេលណា ខណៈណា មានហេតុណាមួយឬអារម្មណ៍ណាមួយកើតឡើងចំពោះព្រះភក្ត្រឬក្នុងព្រះទ័យរបស់ព្រះអង្គ , ព្រះអង្គត្រូវប្រើអាវជ្ជនៈ ពិចារណារំពឹងមើលភ្លាម ៗ ទ្រង់ក៏បានជ្រាបច្បាស់ យល់ច្បាស់ នូវហេតុឬអារម្មណ៍នោះៗ ក្នុងកាលទាំងបី ដោយអាការសព្វគ្រប់ ឥតបន្លោះ ក្នុងទីនោះ

ពេលនោះ ខណៈនោះឯងដោយពុំចាំបាច់គិតទុកជាមុនឡើយ ។

ព្រោះ ហេតុអ្វី ? ព្រោះញាណរបស់ព្រះអង្គមានគ្រប់គ្រាន់បរិបូណ៌ទោះបីគេសួរ ផ្ចួនឆ្លើយភ្លាម ៗ ចំពោះ ហេតុក្នុងកាលជាអតីតអនាគត ឬ បច្ចុប្បន្ន , ព្រះអង្គ អាចឆ្លើយបានភ្លាម ៗ ដោយអាការសព្វគ្រប់ ឥតមានខ្វែសខ្វាល់ ។ ព្រោះហេតុនោះ ការគិតទុកជាមុន ជាការខូចពេលឥតប្រយោជន៍ ដោយព្រះអង្គជាអ្នកសន្សំពេល វេលាជាទីបំផុត ។

សេចក្ដីបំណោះ សរឲ្យឃើញថាសព្វញ្ញុតញ្ញាណរបស់មហាវីរៈនិងព្រះសម្មាសម្ពុទ្ធ ជាម្ចាស់របស់យើងមានសេចក្ដីពិសេសប្លែកពីគ្នាយ៉ាងណា ។

បប់ដោយសង្ខេប

ភិក្ខុវីរបណ្ឌិតោ (អាំ-សួន ហៅហម)

Nalanda Meha Vihàra, Nalanda P. O., Patna Dist, India

---

# បុរាណភាគនិវាសន៍ (តនឹងបប់)

វេលានោះ ចៅអធិការ ល្វី-ឯម បានចាត់ការឲ្យមើល ធ្វើឈើព្រៃទាំងនោះ ឡូជាទីវាលស្អាត រាតទីវត្តឲ្យរីកធំសមល្មមដល់មកសព្វថ្ងៃនេះ, កន្លែងណាដែល មានថ្មុកផ្ទុក បានឲ្យសាមណេរ កុមារដញ្ជូនដីពីទីខ្ពស់មកចាក់លប់ទីកន្លែងនោះឲ្យរាប ស្មើធេងរលីងស្អាត កុំឲ្យមានទឹកដក់នៅ ទាំងបានកសាងកុដិធំតូចសម្រាប់ឲ្យភិក្ខុ- សាមណេរជ្រកនៅរៀនសូត្រ ធ្វើសាលាធំ ១ ខ្នងសម្រាប់ទាយក-ទាយិកាធ្វើបុណ្យ ទាន មានទាំងដើមដូង ដើមក្រូចពោធិសាត់ ដើមត្នោតបែក ដើមទៀបជាដើម ឲ្យ

សមជាអារាមគួរជាទីជ្រះថ្លាដល់មហាជនដែលចូលមកគោរពបូជាធ្វើបុណ្យទាន ឥឡូវនេះ របស់ទាំងនោះវិនាសបាត់បង់អស់ខ្លះហើយ, វត្តព្រះរាជនិវេសនដ្ឋាននេះ ដែលត្រឡប់បានរុងរឿងឡើងដល់ម្ល៉េះ អាស្រ័យដោយបុញ្ញប្បការនឹងកម្លាំងសទ្ធាជ្រះថ្លារបស់ចៅអធិការ ល្វី-ឯម ដែលមានព្រះទ័យមិនរួញរាក្នុងការកុសល បានលះមច្ឆរិយធម៌ហើយ បរិច្ចាគលាភៈសក្ការៈដែលកើតឡើងចំពោះខ្លួនកសាងកុដិសាលាទុកជាស្នាព្រះហស្តអស់បច្ច័យរាប់ម៉ឺនរៀលក្នុងទីវត្តស៊ីធរនោះ ព្រោះតែការរៀបចំសម្អាតឲ្យមានអនាម័យដ៏ល្អដូចជាវត្តលង្កាសព្វថ្ងៃនោះដែរ គួរនឹកគុណូបការៈធ្វើមនសិការៈទុកក្នុងចិត្តរបស់យើងខ្ញុំចំពោះឧត្តមគុណដ៏ថ្លៃថ្លាបណ្ដូលបណ្ដាច់នេះ ។

ចៅអធិការ ល្វី-ឯម គង់នៅជាសុខសប្បាយជាមួយនឹងសិស្សានុសិស្ស ឧបាសកឧបាសិកាក្នុងទីវត្តព្រះរាជនិវេសនដ្ឋាន ស្រីសឈរបាន១៣ព្រះវស្សា ស្រាប់តែពេលនោះមានសំបុត្រពីព្រះតេជព្រះគុណព្រះមហាវិមលធម្មនាម (ថោង) លោកអ្នកឧកញ៉ាយោមរាជ.ម៉ែន លោកស្រីជំទាវព្រាប ឲ្យនិមន្តវិលត្រឡប់ទៅធ្វើជាចៅអធិការវត្តលង្កា ក្រុងភ្នំពេញវិញ លោកក៏បានបំរើនពរលាឧបាសក-ឧបាសិកា សិស្សានុសិស្សលះបង់ចោលអារាមវត្តនោះ ត្រឡប់ទៅគង់នៅភ្នំពេញ តែព្រះទ័យនៅមានមេត្តាករុណាអាណិតអាសូរអាលោះអាល័យទីកើតដំណែលវត្តមិនលះបង់ចោល បានចាត់ឲ្យព្រះថេរៈ១រូបឈ្មោះ (យស់-សុខ) ធ្វើជាចៅអធិការជំនួស ឥតអំពីចៅអធិការ (យស់-សុខ)ទៅ, បានចាត់ព្រះថេរៈចាស់១អង្គទៀតព្រះនាម (ម៉ា-សៀង) ឲ្យធ្វើជាចៅអធិការជំនួសតមក ។

លោកគ្រូព្រះនាម (ម៉ា-សៀង) ទើបតែនិមន្តមកពីស្រុកបាងកក ជាអ្នកចេះប្រែបាលីព្រះត្រៃបិដក ព្រះតេជព្រះគុណចៅអធិការ ល្វី-ឯម នឹងព្រះតេជព្រះគុណព្រះមហា

វិមលធម្ម នាម (ថោង) បានចាត់លោកឲ្យនិមន្តមកធ្វើជាចៅអធិការវត្តព្រះពជនិវេសន-ដ្ឋាននេះ តាមសេចក្តីនិមន្តរបស់លោកតា (បញ្ញា-ចាប)នោះទៀត ។

លោកគ្រូព្រះនាម ម៉ា-សៀង បានទទួលនាទីឡើងជាចៅអធិការស៊ប់ហើយ លោកបានបង្ហាត់បង្រៀនភិក្ខុ-សាមណេរប្រែបាលីព្រះត្រៃបិដក ពួកកុមារឲ្យសិក្សារៀនអក្សរសាស្ត្រតាមទំនៀមទំលាប់ ទាំងជួសជុលថែទាំសម្អាតវត្តអារាមទាំងមូល មានកសាងជញ្ជាំងវិហារតូចវិហារធំអំពីស៊ីម៉ង់ត៍ផង ក្រាលឥដ្ឋពណ៌ រៀបឥដ្ឋទីជើងវិហារទប់ដីកុំឲ្យបាក់ធ្លាក់ចុះទៅទីដទៃ កសាងសាលាបាលីរង កសាងកុដិធំ ១ ខ្នងអំពីស៊ីម៉ង់ត៍ផងជាដើមទុកជាអនុស្សាវរីយវត្ថុ លុះដល់ព្រះជន្មាយុ ៦៨ ឆ្នាំ លោកក៏បានសុគតទៅនៅខែជេស្ឋ អស់ពួកសិស្សានុសិស្ស ឧបាសក ទាយក-ទាយិកា មានសេចក្តីសោកស្តាយពន់ពេក ព្រោះលោកជាអ្នកមានគុណូបការៈចំពោះវត្តនេះជាអនេក ។

កាលដែលផុតអំពីចៅអធិការព្រះនាម (ម៉ា-សៀង) ទៅហើយ សម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា ល្វី-ឯម កាលដែលព្រះអង្គលោកលះបង់នាទីពីចៅអធិការវត្តព្រះពជនិវេសនដ្ឋានស្រីសឈរនោះមកធ្វើជាចៅអធិការវត្តលង្កា ឡើងសមណ-ស័ក្តិងារជា ព្រះញាណបវរវិជ្ជា, ព្រះសិរីសម្មតិវង្ស, ព្រះធម្មលិខិត, ដល់ទីបំផុតសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សាវត្តលង្កានេះ ព្រះអង្គលោកបានចាត់លោកព្រះគ្រូវិរិយមុនី (សៅ-មៀច) ជាអាចារ្យសាលាបាលីរងវត្តលង្កាឲ្យទៅធ្វើជាចៅអធិ-ការបណ្តោះអាសន្នចំនួន ៣ ឆ្នាំនៅវត្តព្រះពជនិវេសនដ្ឋាននោះ ជំនួសលោកគ្រូចៅអធិការព្រះនាម (ម៉ា-សៀង) ហើយឲ្យត្រឡប់មកនៅវត្តលង្កាដដែលវិញ ។

សម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា ល្វី-ឯម កាលដែលឲ្យព្រះគ្រូវិរិយមុនី សៅ-មៀច ត្រឡប់មកគង់នៅភ្នំពេញវិញ ក៏បានបង្គាប់ឲ្យព្រះគ្រូ សៅ-មៀច ព្រមទាំងឧបាសក-ឧបាសិកា អាចារ្យសម្រាប់វត្ត ប្តឹងរាជការសុំរើសរកភិក្ខុគង់វត្ត១រូបធ្វើជាចៅអធិការ ដើម្បីឲ្យគ្រប់គ្រងទីវត្តនោះតទៅ រាជការក៏បានរើសយកលោកអាចារ្យ បិន-សយ ដោយសេចក្តីព្រមព្រៀងរបស់ភិក្ខុសាមណេរផង ឧបាសក-ឧបាសិកាជាអ្នកអបរណបផង តាមផ្លូវរាជការ, លោកអាចារ្យ បិន-សយ បានឡើងនាទីជាចៅអធិការវត្តព្រះរាជនិ-វេសនដ្ឋាន ស្រីសឈរតាមផ្លូវការ ទាំងដោយតេជានុភាពរបស់សម្តេចផង ភិក្ខុសង្ឃផង ក៏បានចាត់ការរៀបចំវត្តតាមថេរប្បញ្ញារបស់សម្តេចឲ្យទាន់សម័យ គឺបានកសាងសាលាបឋមសិក្សា១ខ្នងមានបំនួន៣ថ្នាក់ សម្រាប់កុមារ-កុមារីទាំងឡាយរៀនសូត្រ, សាលាសម្រាប់ទាយក-ទាយិកា ធ្វើបុណ្យទាន, ធ្វើរបងស៊ីម៉ង់ត៍បង់របាលួសបន្ទាត់ខ្ទជុំវិញវត្ត, គឺទទួលសេចក្តីគោរពចំពោះសម្តេច ដែលបានប្រទាន បច្ច័យ ១ ម៉ឺនរៀលឲ្យរៀបចំកសាងទុកជាកេរ្តិ៍ដំណែលរបស់ព្រះអង្គលោកតមកទៀត កុំឲ្យរលាយរលប់វិនាសបាត់បង់របស់ទាំងនេះ ដែលកើតឡើងដោយកម្លាំងសទ្ធាជ្រះថ្លារបស់សម្តេច ដែលតាំងព្រះទ័យទុកទីកន្លែងវត្តនេះ ថាជាកេរ្តិ៍ដំណែលពុទ្ធសាសនប្បវេណីរបស់ព្រះអង្គលោកមិនលះបង់ចោល បានប្រតិស្ឋានទុកឲ្យសិស្សានុសិស្ស, គួរឲ្យសរសើរចំពោះព្រះអង្គលោកថា: «មិនប្រាថ្នាសេចក្តីសុខត្រឹមចំពោះខ្លួនប៉ុណ្ណោះ ហើយទម្លាក់ទោសទុក្ខទៅលើអ្នកដទៃ សមដូចភាសិតដែលគេសរសើរមនុស្សថា: មនុស្សណាដែលរស់នៅ ត្រូវខំប្រឹងធ្វើអ្វីមួយទុកឲ្យជាប្រយោជន៍ដល់ពួកជនដែលរស់នៅខាងក្រោយ កេរ្តិ៍ឈ្មោះរបស់មនុស្សនោះឈ្មោះថាមិនស្លាប់ គឺថាជាអ្នកបែក

សេចក្តីសុខទៀតដល់គេ ,, នេះហើយ ត្រូវយើងដឹងគុណបូជការៈចំពោះសម្តេចដែលបាន ញាំងព្រះពុទ្ធសាសនានៅវត្តស៊ុធរនេះឲ្យជាស្ថាពរតទៅអនាគត ដើម្បីជាប្រយោជន៍ ឲ្យប្រាកដជាក់ស្តែងឡើង ពណ៌នាអំពីបុណ្យកឋិនវិសេសនៅទីកន្លែងដំបន់ឃុំស៊ុធរ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ចប់ដោយសេចក្តីសង្ខេបតែប៉ុណ្ណេះ ។

លំដាប់អំពីនេះ សូមពណ៌នាអំពីបុណ្យធ្វើរបងវត្តព្រះរាជនិវេសនដ្ឋានស្រីសណ្ឋរ កាលនៅថ្ងៃ ២កើតខែចេត្រ ព.ស.២៤៩៨ត្រូវនឹងថ្ងៃ ១៣ ខែមីនា (មារ្ស) គ.ស ១៩៥៦សម្តេចបានទទួលនិមន្តចៅអធិការ ចិន-សយ នឹងអាចារ្យសម្រាប់វត្តព្រះរាជនិវេសនដ្ឋានស្រីសណ្ឋរ ទៅធ្វើបុណ្យរបងវត្តដោយនាវា (កាណូត) តូច១ បានចេញដំណើរពីភ្នំពេញទៅនៅវេលាម៉ោង ៧ ព្រឹក, ដល់ពេលម៉ោង ៦ ល្ងាចទើបដល់វត្តស៊ុធរនោះ ជួបជុំព្រះសង្ឃនិងឧបាសក ឧបាសិកាប្រហែលជា ៧០០រូប រង់ចាំទទួលពីផែនាវា រហូតដល់វត្តស៊ុធរ កងពេលធ្វើបុណ្យនោះ គេបានសំគាល់ឃើញការ តាក់តែងភ្លើងអគ្គិសនីដាក់ជាជួរតាមក្បាលរបងវត្តលាតសន្ធឹងយ៉ាងវែង ទាំងខ្វាត់ខ្វែងក្នុងទីទទឹងសព្វអន្លើក្នុងព្រៃព្រោត ទាំងប្រកបដោយតន្ត្រីស្រីប្រុសច្រៀងឆ្លើយឆ្លងគ្នាទៅវិញទៅមកអស់រយៈ ៣ រាត្រី ទើបសម្រេចការធ្វើបុណ្យរបងនោះ ដែលគួរឲ្យរីករាយសប្បាយអស្ចារ្យក្នុងពិធីបុណ្យនោះ ដោយមានមនុស្សអញ្ជើញមកអបអរសាទរអនុមោទនា ណែនណាន់តាន់តាប់ចំពោះបុណ្យក្នុងវត្តស៊ុធរនោះ លុះពេលព្រឹកម៉ោង ៦ ក្តី សម្តេចបានប្រទានពរលាឧបាសក-ឧបាសិកា ទាំងចៅអធិការ គុក-សាមណោរីល ត្រឡប់មកភ្នំពេញដោយកាណូតជាសុខសួស្តី ។

ទីបំផុតនៃបរិយោសានកាសនេះ យើងសូមធ្វើនូវសច្ចកិរិយាជាសាមគ្គីរួម

គំនិតគ្នា ផងចិត្តដោយស្មោះសរជ័បរិសុទ្ធដែលកើតអំពីកុសលធម៌នៃការធ្វើបុណ្យរបង វត្តនេះ លើកឧទ្ទិសដោយសុទ្ធចិត្ត ថ្វាយជាកុសលផលចំពោះព្រះករុណាជាម្ចាស់ជីវិត, សម្តេចព្រះមហាក្សត្រិយានី ព្រមទាំងសម្តេចព្រះឧបយុវរាជ សូមទ្រង់ប្រកបដោយជោគជ័យសេចក្តីសុខ-ចំរើនក្នុងសិរីរាជសម្បត្តិ អស់កាលជាអង្វែងតទៅអនាគតកុំបីឃ្លៀងឃ្លាតឡើយ ។

សូមឧទ្ទិសកុសលនេះ ចំពោះសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា សូមឥទ្ធានុភាពរបស់កុសលនេះ ជាវត្ថុស័ក្តិសិទ្ធជាកម្លាំងជួយអភិបាលរក្សាសម្តេចឲ្យមានកម្លាំងព្រះកាយរឹងប៉ឹងដោយវាយោអស្សាសប្បស្សាសៈជួយជាជំពារទ្រករដ្ឋកាយនោះឲ្យបរិបូណ៌ឡើងវិញ ហើយសូមឲ្យមានព្រះជន្មវែងអស់រយៈនៃវស្សាតទៅអនាគតកុំបីឃ្លៀងឃ្លាតឡើយ ។

សូមឧទ្ទិសកុសលនេះ ជូនចំពោះអស់លោកអ្នកពុទ្ធបរិស័ទទាំងឡាយទោះបីនៅភូមិស្រុកជិតឆ្ងាយក៏សូមឲ្យបានប្រកបដោយជោគជ័យសេចក្តីសុខ-ចំរើនគ្រប់រូបគ្រប់ក្រុមគ្រប់គ្រួសារទាំងសត្វទ្វេបាទ, ចតុប្បាទ, ពហុប្បាទ, អបាទ សូមឲ្យផុត, ប្រាសចាក, និរទុក្ខ, និរភ័យ, ចង្រៃ, ឧបទ្រព, អពមង្គល, វល់គំនិត, គិតមិនឃើញ, សូមឲ្យបរវៀសបៀសវាងកុំឲ្យចូលមកជិតដិតដាក់ប្រឡាក់ដោយសន្តានចិត្ត របស់អស់លោកអ្នកសប្បុរសតរៀងទៅអនាគត កុំបីឃ្លៀងឃ្លាតឡើយ,

សូមឧទ្ទិសកុសលនេះ ចំពោះទេពនិករទាំងឡាយមានអារក្ខអារ័ក្សទេព្រក្សឥសីសីលាសាងសីលទាន ទីងទេវតារក្សាអារាមវត្តព្រះរាជនិវេសនដ្ឋាននេះជាដើមសូមឲ្យបានប្រកបដោយសេចក្តីសុខ-ចំរើនសិរីសួស្តីជ័យជាទិពកុំឲ្យនិរាសឃ្លៀងឃ្លាតចាក របស់ទិព

ឡើយ ។

អ្នកចងក្រងរឿងបុរាណនិទេសន៍

ព្រះពុទ្ធវង្ស កៅ-ស៊ុម

អាចារ្យបង្រៀនសាលាពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រុងភ្នំពេញ, គង់នៅវត្តលង្កា

អ្នករៀបរៀងចងក្រងតាមលំអានស្ថានភាពបុរាណនិទេសន៍នៅភូមិភាគដំបន់នោះ ។

បប់

## ជ័យប្រាជ្ញ (ត)

អម្បាលក្មេងនៅតូចប៉ុនខ្ញុំ ៗ មិនជឿថា ព្រះមហាក្សត្រត្រាស់ប្រើឲ្យអស់លោកមកចាប់ចងទេ បើប្រើឲ្យចាប់ចងក្រែងតែព្រះមហាក្សត្រអង្គណាដែលប្រកបដោយសេចក្ដីល្ងង់ខ្លៅ ទើបអាចបើកព្រះឱស្ឋឲ្យចាប់ចងសត្វបើកូនក្មេងនូវដំណូចប៉ុណ្ណេះកើត មួយទៀតទ្រង់ទទួលនូវខសន្យាវាំងលោកនឹងខ្ញុំរួចទៅហើយ មិនមែនទ្រង់ប្រើមកឲ្យធ្វើយ៉ាងនេះទេ ។ ពាក្យដែលខ្ញុំនិយាយប៉ុណ្ណេះ សូមអស់លោកពិចារណាមើល តើជាការគួរ ឬ មិនគួរ បើអស់លោកនៅតែទទូចចង់ចាប់ចងខ្ញុំទៀតក្រែងលោ ......,. សូមទានគិតឲ្យច្បាស់សិនទៅ ។

អាមាត្យង៉ាកមើលមុខគ្នាឡើងឡង់ ហើយនិយាយគ្នាថា បើដូច្នេះ ត្រូវអ្នកណាម្នាក់ទៅក្រាបបង្គំទូលព្រះមហាក្សត្រឲ្យបានសព្វគ្រប់តាមដំណើរនេះសិន ទើបបានផលល្អ ។

អាមាត្យម្នាក់បាននាំសេចក្ដីនោះទៅក្រាបបង្គំទូលព្រះមហាក្សត្រដោយហួរហែ ៗ ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ហើយមានព្រះបន្ទូលថា ណ្ហើយ ! គ្រាន់តែចាប់ដឹកដៃវានាំមកបានហើយ មិនបាច់ចាប់ចងវាធ្វើអីទេ ៗ

អាមាត្យនោះត្រឡប់មកវិញហើយនិយាយប្រាប់អាមាត្យនៅទីនោះថា ព្រះមហាក្សត្រឲ្យគ្រាន់តែចាប់ដឹកដៃវាយកទៅ មិនឲ្យចាប់ចងវាទេ ៗ

ពួកអាមាត្យទាំងនោះក៏ចាប់ដឹកដៃកុមារជ័យយកទៅថ្វាយព្រះមហាក្សត្រ ៗ កុមារជ័យដើរបណ្ដើរនិយាយបណ្ដើរថា នុះ ! បងឯង ! ខ្ញុំថាមិនខុសមែន បើនៅតែទទូចចាប់ខ្ញុំចងយកទៅ បងឯងច្បាស់ជាត្រូវទណ្ឌកម្មរបស់ព្រះមហាក្សត្រមិនខាន ៗ បើនិយាយឲ្យត្រឹមត្រូវតាមលក្ខន្តិក ត្រូវតែបងឯងដឹងគុណខ្ញុំ ព្រោះបងឯងបានរួចទោសអំពីការប្រព្រឹត្តល្មើសនឹងបទព្រះបញ្ជា ឬ ខុសសន្យានោះ ដោយសារតែខ្ញុំជួយការពារទេ ៗ កុំអីបងឯងទាំងអស់គ្នា នឹងត្រូវទទួលទោសមុនខ្ញុំទៅទៀត ៗ នេះគួរតែសរសើរសំណាងខ្លួនទៅ ដោយបានមកជួបនឹងខ្ញុំ បើប្រសិនជាជួបនឹងអ្នកឯទៀត ប្រហែលជាគេសម្ងំយកទោសឥតត្រាប្រណីឡើយ ៗ អស់លោកមុខជាត្រូវទោសគ្រប់គ្នាមិនខាន ៗ លុះអាមាត្យបាននាំកុមារជ័យចូលទៅដល់ព្រះមហាក្សត្រហើយ ព្រះមហាក្សត្រត្រាស់បណ្ដេញពួកអ្នកគាល់បំរើទាំងប៉ុន្មានឲ្យចេញមកក្រៅទាំងអស់ មិនឲ្យអ្នកណាមួយនៅក្បែរឡើយ ឯចំណែកពួកអស់អ្នកក៏ទ្រង់មិនឲ្យនៅស្ដាប់ការដែរ ៗ ទ្រង់ត្រាស់សួរទៅកុមារជ័យផ្ទាល់ថា នែ ! អាជ័យ ! ហេតុអ្វី ក៏អាឯងវាយអស់អ្នកយ៉ាងនេះ ៗ

កុមារជ័យសូមទ្រង់ព្រះមេត្តាប្រោស ! ទូលព្រះបង្គំគ្មានប្រាថ្នានឹងវាយសោះប៉ុន្តែ

ទូលព្រះបង្គំយល់ឃើញថា អ្នកបង់ទាំងនេះ ប្រាកដជាប្រព្រឹត្តផ្ទុយនឹងព្រះរាជឧង្ការដែលមានទំនងដូចតទៅនេះ ៖

១– កំហុសរបស់ទូលព្រះបង្គំបើជាមាន នោះព្រះអង្គអាចសម្រេចទៅតាមផ្លូវច្បាប់បានទាំងអស់ មិនចាំបាច់ប្រើមនុស្សឲ្យទៅផ្ទុះអាចម៍ដាក់ផ្ទះទេ ព្រោះផ្ទះជារបស់ឥតវិញ្ញាណ មិនអាចប្រព្រឹត្តការជំទាស់នឹងព្រះរាជបញ្ញត្តិបានឡើយ ។ អំពើនេះពិតជាធ្វើដោយចិត្តឯង ហើយយកនាមព្រះអង្គទៅបញ្ចេញយកអំណាចដែលជាហេតុនាំឲ្យខូចកិត្តិយសរបស់ព្រះចេស្ដាថែមទៀត ។

២– កាលទ្រង់ជំនុំជំរះពីប៉ុន្មានថ្ងៃមុននោះ ទ្រង់បានមានព្រះបន្ទូលផ្ដាំផ្ញើលឲ្យពួកអ្នកបង់ទាំងនោះថា “មានតែឲ្យអញប្រើឯងរាល់គ្នាឲ្យទៅផ្ទុះអាចម៍ដាក់ផ្ទះវាតែម្ដងទើបបានស្កប់ចិត្តឯងរាល់គ្នាឬអី ?” ព្រះរាជបន្ទូលនេះ ក្រែងអ្នកបង់ទាំងអស់នោះស្ដាប់សេចក្ដីមិនបាន ស្មានតែព្រះអង្គត្រាស់ប្រើមែន ហើយនាំគ្នាទៅផ្ទុះអាចម៍ដាក់ផ្ទះទូលព្រះបង្គំតែម្ដងទៅ ។

៣– បើប្រឡូមែន នោះទូលព្រះបង្គំក៏មិនប្រកាន់ដែរ ព្រោះបានជាជ្រលមានព្រះឧស្ហមានព្រះបន្ទូលថា “ឲ្យទៅផ្ទុះ” មែន ប៉ុន្តែពួកអ្នកបង់ទាំងនោះមិនគ្រាន់តែផ្ទុះថែមនោមផង ឃើញថាប្រព្រឹត្តផ្ទុយនឹងព្រះរាជឧង្ការពិតប្រាកដមែន ទើបទូលព្រះបង្គំអត់ទ្រាំមិនបានយករឿងវាយទៅ ។

៖ ដែលទូលព្រះបង្គំក្រាបទូលទាំង៣នេះប្រកបដោយមនោសញ្ចេតនា២យ៉ាងគឺ

១– ទូលព្រះបង្គំវាយដើម្បីផ្ដន្ទាទោសមនុស្សដែលប្រព្រឹត្តកន្លងព្រះរាជឧង្ការ កុំឲ្យហ៊ានប្រព្រឹត្តដូច្នេះតទៅទៀត ។

២.– ទូលព្រះបង្គំរាយដើម្បីលើកកិត្តិយសព្រះអង្គឲ្យល្បីឮទៅថា ព្រះមហាក្សត្រទ្រង់ត្រង់ពាក្យដោយថ្លៃថ្នូរ ទ្រង់មិនប្រព្រឹត្តនិងមិនប្រើឲ្យគេប្រព្រឹត្តនូវអំពើអយុត្តិធម៌ណាមួយឡើយ ។ ការប្រព្រឹត្តនេះ ចេញមកពីគំនិតរបស់សាមីខ្លួនផ្ទាល់ ។

សូមទ្រង់ជ្រាប ។

ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ហើយមានព្រះបន្ទូលតបទៅកុមារជ័យវិញថា នែ៎អាជ័យ ! រឿងនេះអញវិនិច្ឆ័យទៅឃើញច្បាស់ដូចជាពាក្យឯងបានឆ្លើយមកទាំងប៉ុន្មានហើយ ។ បំណែកអស់អ្នកទាំងនេះសុទ្ធតែជាអ្នកប្រព្រឹត្តល្មើសពេញទី ប៉ុន្តែណ្ហើយបុះបើអញកាត់ឲ្យឯងឈ្នះមុខជាកើតសេចក្ដីព្យាបាទកាន់តែខ្លាំងឡើង ការព្យាបាទនោះគេអាចប្រព្រឹត្តដោយផ្លូវកំបាំងដែលឥតកស្ដាងក៏បាន ហេតុនេះអញសុំចិត្តឯងថា សូមឲ្យឯងតាំងសេចក្ដីស្ងប់ស្ងាត់ពីថ្ងៃនេះតទៅ ។ មួយទៀតសូមឲ្យឯងចេញពីវាំងនេះទៅនៅផ្ទះខ្លួនតាមធម្មតាវិញទៅ ។ អញមិនក្ខេបឯងទេ អញទុកឯងស្មើនឹងបុត្ររបស់អញ ប៉ុន្តែការដែលអញឲ្យឯងទៅនៅផ្ទះជាធម្មតានេះ អញធ្វើហាក់ដូចជាបណ្ដេញឯងឲ្យចេញពីក្នុងវាំងនេះទៅ នៅចំពោះមុខអស់អ្នកទាំងឡាយនោះ ដើម្បីឲ្យគ្រាន់តែគេអស់ចិត្តប៉ុណ្ណោះ ។ សព្វថ្ងៃនេះឯងនៅតូចណាស់ហើយមានបញ្ញាលប់មាឌឈ្នះគេឈ្នះឯងគ្រប់គ្នា ដែលជាហេតុនាំឲ្យគេក្ដៅក្រហាយចំពោះរូបឯង ។ បើប្រសិនជាថ្ងៃណាមួយគេនាំគ្នាសម្លាប់ឯងចោលទៅ អញមិនអាចនឹងរកអ្នកណាមួយជាគូប្រៀបនឹងឯងឲ្យត្រឹមស្មើបានឡើយ ។ ហេតុនេះបួរឯងគេចទៅនៅផ្ទះឲ្យផុតសត្រូវសិនទៅ ។ កាលណាឯងមានវ័យតាំងនៅក្នុងទីតិកាព សឹមអញយកឯងមកឲ្យជួយធ្វើការតទៅថ្ងៃមុខ ។

កុមារជ័យ– បើព្រះអង្គទ្រង់មានសេចក្ដីសង្គ្រោះដូច្នេះ នោះទូលព្រះបង្គំមានសេចក្ដីត្រេកអរជាទីបំផុត សូមទទួលព្រះរាជទុក្ការដោយគោរព ! ។

បន្ទាប់ពីនេះព្រះមហាក្សត្រទ្រង់ត្រាស់ឲ្យហៅពួកអស់អ្នកទាំងនោះមកដល់ហើយទ្រង់ធ្វើហាក់ដូចជាខ្វល់ខ្វាំងហើបណ្ដេញកុមារជ័យថា ហ្នៃ៎ ! អាជ័យ ! ត្រូវអាឯងចេញឲ្យផុតស្រឡះពីវាំងអញទៅ កុំនៅស្ដាប់ការអីទៀត ព្រោះអាឯងនេះខូចណាស់ ។

X

X X

កុមារជ័យក្រាបថ្វាយបង្គំលាព្រះមហាក្សត្រចេញទៅកាន់ផ្ទះរបស់ខ្លួនតាមធម្មតាវិញ ខំយកទឹកលាងលាមកស្អាតអស់រលីង ។

ចំណែកអ្នកឯក នឹងនាងកាណាត្រឡប់មកដល់ផ្ទះវិញហើយធុំក្លិនលាមកស្អុយល្ហុំពេញតែផ្ទះ ក៏សួរទៅកុមារជ័យថា នែ ! កូន ! ធុំក្លិនស្អុយលាមកពីណាខ្លាំងម៉្លេះ ។

កុមារជ័យ– បពិត្រលោកម្ដាយ ! លោកឪពុក ! កូនគេឡើងមកលេង ហើយវាពកអាចម៍ដាក់ផ្ទះយើង នៅវេលាព្រឹកមិញនេះ ។

ឯក នឹងនាងកាណាក៏នៅស្ងៀមឥតមានសួរការអ្វីទៀតឡើយ ។

កុមារជ័យក៏នៅជាសុខជាមួយនឹងមាតាបិតា ខំជួយធ្វើការផ្ទះនឹងការវាល ដូចជាក្មេងឯទៀត ។

ចំណែកព្រះមហាក្សត្រទ្រង់ត្រាស់ហៅឲ្យពួកអស់អ្នកទាំងនោះ ចូលមកកាន់សំណាក់ព្រះអង្គម្នាក់ម្ដងៗ ទ្រង់ត្រាស់សួរហេតុសព្វគ្រប់ត្រាតែគ្រប់គ្នា ហើយទ្រង់បញ្ជាក់ថា ចូលនាងទាំងឡាយកុំអាក់អន់ចិត្ត ចំណែកអាជ័យអញដេញឲ្យវាទៅនៅផ្ទះ ឈប់ឲ្យចូលវាំងទៀតហើយ ព្រោះវាខូចណាស់ ។ ពួកអស់អ្នកក៏មានសេចក្ដីរីករាយ

សប្បាយគ្រប់គ្នាតាំងពីថ្ងៃនោះមក ។

កុមារជ័យពិចារណាក្នុងចិត្តថា ការនៅក្នុងសំណាក់មាតាបិតាជាការធម្មតា ដោយហេតុគ្មានបញ្ហាប្លែក គឺនិតផ្ទែក នឹងបំណោះផ្ទែកដែលជាគ្រឿងធ្វើខ្លួនឲ្យពិសេសតទៅខាងមុខទៀតសោះ បើដូច្នេះអញចេញទៅនៅនឹងអ្នកដទៃវិញល្អជាង តែមិនត្រូវធ្វើខ្លួនឲ្យជាប់បំណុលគេទេ ដើម្បីឲ្យងាយនឹងដើរចេញពីគេ ។

សម័យនោះប្រទេសគោកធ្លកកំពុងតាំងនៅក្នុងយុគៈដ៏ចំរើន មានជនបរទេសចេញចូលមករកស៊ីជាច្រើនសាសន៍ ។ នៅក្នុងភូមិរបស់កុមារជ័យនោះមានសេនាបតីចិនម្នាក់ ត្រូវស្តេចក្រុងចិនទិរទេសចេញពីស្រុកចិនចូលមកនៅក្នុងប្រទេសខ្មែរ ។ សេនាបតីនោះជាអ្នកមានបំណះវិជ្ជាយ៉ាងជ្រៅជ្រះ មករកស៊ីកើនទ្រព្យសម្បត្តិយ៉ាងបរិបូណ៌ ដូចជាខ្លួនកំពង់ទទួលកិត្តិយសនៅប្រទេសចិនដែរ ។ នៅក្នុងទីផ្សារមានជាតិពកទុយក្រូ, ជាតិរូម, ជាតិក្វង, និងជាតិភូមា-មាទិលជាដើម ។ល។ នៅប្រកបការរកទទួលទានជាអ្នកជំនួញនៅទីផ្សារ ។

កុមារជ័យនិយាយទៅកាន់មាតាបិតាថា បពិត្រលោកអ្នកដ៏មានគុណ កូនបានទៅលេងផ្ទះចិនម្នាក់ ឃើញមាននុំនឹងសាច់ជ្រូកស៊ីច្រើនណាស់ ហេតុនេះកូនចង់ញ៉ាំនុំនឹងសាច់ជ្រូកឥតឧបមា សូមលោកម្តាយលោកឪពុកយកខ្ញុំទៅទុកឲ្យនៅបំរើចិននោះទៅ ទើបខ្ញុំសុខចិត្ត បើមិនដូច្នោះទេ កូនមុខជាចុះទៅស៊ីឈ្នួលសំពៅដើរចោលស្រុកចេញទៅប្រទេសក្រៅមិនខានឡើយ ។

(នៅមានត)

# ធនញ្ជ័យបណ្ឌិត(ត)

## បណ្ឌិតវិនិច្ឆ័យគាថាទី ៣

ឱកាសនេះនឹងសំដែងពីការរើសរកអ្នកប្រាជ្ញ ដែលគួរលើកឡើងតាំងឲ្យបានទុក សម្រាប់ប្រទេស, នគរ, ដើម្បីថ្កុំថ្កើងរុងរឿងតាមបែបផែនគម្ពីរបូរាណ ៗ

បណ្ដាមនុស្សដែលចេះដឹងពិត ហើយប្រតិបត្តិតាមគន្លងច្បាប់ផងក្រពេកណាស់ ច្រើនតែមនុស្សល្ងង់ខ្លៅហើយប្រព្រឹត្តទុច្ចរិតឥតកោតញញើតផងទៀត ងាយណាស់ ស្ទើរតែពេញលោកទាំងមូល ៗ មហាក្សត្រពីដើម កាលណាត្រូវការតាំងមនុស្សណាមួយឲ្យកាន់ការគ្រប់ដំណែង ព្រះអង្គប្រជុំមហាមន្ត្រីដែលមានប្រាជ្ញាចាស់ ៗ មានចិត្តជាកណ្ដាលមិនលម្អៀងដោយអគតិទាំង ៤ ឲ្យប្រជុំជ្រើសរើសរករូបអ្នកប្រាជ្ញ ដោយពិធីបោះឆ្នោតឬក៏ប្រឡងដើម្បីជៀសវាងស៊ីសំណូកនិងអំពើទុច្ចរិតនោះចេញ ៗ ជួនណាតាំងបញ្ហាចោទសួរអំពីសាធុកិច្ច ឲ្យពួកកុមារតាំងពីអាយុ ៧ ឆ្នាំឡើង បើកុមារណាឆ្លើយរួចឲ្យនាំយកកុមារនោះមកកាន់ទីប្រជុំសន្និបាតនៃស្ដេច ទើបព្រះអង្គបញ្ជាក់ថា ជាអ្នកចេះមែន ៗ និយាយត្រូវពិត ៗ ទើបទ្រង់តាំងក្នុងឋានន្តរស័ក្តិយសតាមគួរ ៗ

## សូមនាំរឿងពីដើម

កាលនោះ ព្រះបាទធនញ្ជ័យគោរព្យរាជត្រាស់សួរបរោហិតថា: «ម្នាលបរោហិត» កុមារឯណាមានប្រាជ្ញាវាងវៃដូចជាធនញ្ជ័យកុមារនេះមានដែរឬទេ ? បរោហិតក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គតាំងជាប្រស្នាសួរឲ្យឆ្លើយគង់នឹងជ្រាបទេ ៗ

ទ្រង់ត្រាស់សួរទៅធនញ្ជយកុមារថា តាតៈហៃកូនសម្លាញ់ កុមារឯណាមានប្រាជ្ញាវៃវាងប្រហែលបាឯងមានទេ ? ធនញ្ជយកុមារក្រាបទូលថា បពិត្រមហារាជ សូមព្រះអង្គជ្រើសរើសមើលស្រុកទាំងបីទៅ គង់នឹងជ្រាបហើយ ។ ត្រាស់សួរថា បុះយើងត្រូវស្គាល់អ្នកប្រាជ្ញដោយលក្ខណយ៉ាងណាកូន ។ សូមឲ្យព្រះវរបិតាសួររកសាធុកិច្ចបញ្ហានឹងកុមារទាំងនោះទៅគង់នឹងស្គាល់ហើយ ។ ទើបទ្រង់ចាត់ប្រើអាមាត្យ៣នាក់ឲ្យចេញទៅស៊ើបរកកុមារអាយុ ៧ ឆ្នាំ បើកុមារណាឆ្លើយសាធុកិច្ចបញ្ហារួចឲ្យនាំយកកុមារនោះមកថ្វាយព្រះអង្គ ។ អាមាត្យទាំងបីរូបទទួលតាមព្រះរាជបញ្ជាថ្វាយបង្គំលាចេញទៅកាន់ស្រុករៀង ៗ ខ្លួន ចំណែកអាមាត្យដែលចេញតាមទ្វារស្រុកខាងត្បូងបានដល់ផ្ទះវិសាលសេដ្ឋី ហើយបង្គាប់ឲ្យប្រជុំកុមារមានអាយុ ៧ ឆ្នាំ បានចំនួន១ពាន់ទារកមកប្រជុំក្នុងបដិសណ្ឋាគារស្ថាន ក៏សួរបញ្ហានឹងកុមារទាំងនោះ ៗ មានតែកុមារម្នាក់ឈ្មោះ "ទេសកណិកាបុត្រ" និយាយដូច្នេះថា បុគ្គលណាមួយក្រោកឡើងអំពីព្រលឹមហើយជម្រះធ្មេញដោយឈើស្ទន់លុបមុខស្អាត បរិភោគអាហារដ៏ឧត្តមរួចដេកលើទីដំណេកដ៏មានសិរីគិតតែស្អិតស្អាងរាងកាយ ហ៊ឹហាសប្បាយគ្រប់តិរិយាបថទាំង៤មិនរវល់ធ្វើការងារអ្វីទាំងអស់ បុគ្គលបែបនេះឈ្មោះថាសាធុជន ជាជនមានកិច្ចល្អពិត ។ អាមាត្យស្តាប់ហើយក៏នាំយកកុមារនោះមកថ្វាយស្តេច ។

អាមាត្យដែលចេញទៅតាមទ្វារស្រុកខាងលិចបានឲ្យសុបិសេដ្ឋី ប្រជុំកុមារអាយុ៧ ឆ្នាំបានពីររយរូបហើយ សួរសាធុកិច្ចបញ្ហានឹងកុមារទាំងនោះ ៗ មានតែម្នាក់គត់ឈ្មោះ "ធុត្តបុត្ត" ឆ្លើយបានថាៈ បុគ្គលណាមានប្រាជ្ញាក្នុងកាមគុណ ៥ គឺរូប, សម្លេង, ក្លិនរស, សម្ផស្សប្រព្រឹត្តស្និទ្ធស្នាលស្នេហាតែក្នុងកាមប៉ុណ្ណោះបុគ្គលនោះ បានឈ្មោះថាសា

ធុជន ជាជនញ៉ាំងកិច្ចល្អពិត ៗ អាមាត្យស្ដាប់ហើយ ក៏នាំយកធុត្តបុត្តកុមារនោះមកថ្វាយ ៗ ឯអាមាត្យដែលចេញទៅតាមទ្វារខាងជើងបានដល់ផ្ទះសុទស្សនសេដ្ឋី ៗ ក៏ចាត់ឲ្យប្រមូលកុមារអាយុ ៧ ឆ្នាំបានប្រាំរយរូប កុមារទាំងនោះមានតែកុមារម្នាក់ឆ្លើយបានថា: បុគ្គលណាពោលពាក្យផរុស្សវាចា ជេរប្រទេចផ្ដាសារ ក្អេងក្អាងឃោរឃៅ ឈ្លះឈ្លានឈ្លៀនពានលើអ្នកដទៃ ឈ្នះគេជានិច្ច បុគ្គលនោះឈ្មោះថាសាធុជន ជាជនញ៉ាំងកិច្ចល្អឲ្យសំរេចពិត ៗ អាមាត្យស្ដាប់ហើយក៏នាំយកតិត្ថមលបុត្តនោះមកថ្វាយ ៗ អាមាត្យទាំងបីនាក់នាំកុមាររៀងៗខ្លួនមកថ្វាយស្ដេចដំណាលគ្នាក្នុងថ្ងៃមួយ ៗ ទើបទ្រង់ប្រជុំនាម៉ឺនសព្វមុខមន្ត្រីព្រមទាំងអ្នកប្រាជ្ញចាស់ ៗ ដើម្បីស្ដាប់បញ្ហាព្យាករណ៍នៃកុមារទាំងបីរូបនោះ ៗ គ្រានោះកុមារទាំងបីនាក់ក៏អធិប្បាយតាមបំណងរៀង ៗ ខ្លួនដូចដែលពោលមករួចហើយនោះ ៗ ព្រះរាជាទ្រង់សណ្ដាប់ព្យាករណ៍កុមារទាំងបីនោះហើយទ្រង់សួរបញ្ឆាក់ទៅបុរោហិតថា ដូចម្ដេចបុរោហិត! យើងល្មមតាំងកុមារនេះឲ្យជាទីអ្នកប្រាជ្ញបានឬទេ? បុរោហិតក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស នេះពិតជាអ្នកប្រាជ្ញហើយ សូមទ្រង់តាំងកុមារទាំងបីនេះទុកក្នុងទីជាឋានន្តរចុះត្រូវហើយ ៗ ព្រះរាជាទ្រង់សួរទៅធនញ្ជយបណ្ឌិត ៗ ក្រាបទូលថា កុមារទាំងបីនាក់នេះ គ្រាន់តែបានឈ្មោះថាជាបុគ្គលឆ្លាតចេះនិយាយប៉ុណ្ណោះ មិនទាន់បានឈ្មោះថាបណ្ឌិតនៅឡើយទេ ៗ ព្រោះហេតុអ្វីបូរអ្នកអធិប្បាយឲ្យយើងស្ដាប់ទៅមើល ? ៗ

ទេវ: បពិត្រព្រះសម្មតិទេព បុគ្គលណាពោលតាមបំណាំ តាមឆ្លាប់ចេះចាំ ដូចទារកដែលពោលសរសើរបុគ្គលស្អិតស្អាងរាងកាយ គិតតែស៊ីដេកហ៊ឺហាសប្បាយហៅថាសាធុជន នេះព្រោះខ្លួនជាកូនពូជស្ដ្រីផាមាស ទារកដែលពោលអួតសេចក្ដីសុខ

ក្នុងកាមគុណទាំង៥នេះថាជាសាធុជនប្រសើរនោះ ព្រោះខ្លួនជាពូជនៃអ្នកលេងល្បែង ។ ទារកដែលពោលអួតសរសើរអំពើផុស្សរ៉ាថា ពេលត្រូវគេបោះបោកទៅរកអ្នកដទៃ នោះថាជាសាធុជនប្រសើរនោះ ព្រោះខ្លួនជាកូនពូជអ្នកចំបាប់ ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយត្រាស់សួរតទៅទៀតថា ចុះលោកអ្នកប្រាជ្ញអាចសំដែងសេចក្ដីនេះដូចម្ដេចវិញសូមសំដែងទៅមើល ? ព្រះធនញ្ជយកុមារក្រាបទូលជាបទព្រះគាថានេះថា :

ន សាធុ អលសោ រាជ ន សាធុ សោ អសញ្ញតោ
ន សាធុ កោធនោ សោច យំ បណ្ឌិត ភាសិតោ ។

បពិត្រមហារាជ បុគ្គលខ្ជិលច្រអូសមិនធ្វើការងារអ្វី គិតតែតែងខ្លួនសប្បាយប៉ុណ្ណោះពុំប្រពៃឡើយបុគ្គលមិនសង្រួមភ្នែក, ត្រចៀក, ច្រមុះ, អណ្ដាត, កាយ ចិត្ត គិតតែមើលរូប, សំឡេង, ក្លិន, រស, សម្ផស្សប៉ុណ្ណោះ មិនបានឈ្មោះថា សាធុជនទេ បុគ្គលដែលក្រោធខឹង គិតតែប្រទូស្តរាយ ឈ្នះឈ្នៀបលើអ្នកដទៃ ពុំបានឈ្មោះថាជាជនញ៉ាំងកិច្ចមានប្រយោជន៍ឲ្យសំរេចឡើយ ពាក្យដែលទូលព្រះបង្គំពោលមកនេះទើបឈ្មោះថាបណ្ឌិតសុភាសិតមែន (សុភាសិតថា ចាំមើលអាការបញ្ចេញពោលពាក្យម្ដេចមិញគន់ដឹងពិត) ។ ព្រះធនញ្ជយបណ្ឌិតគ្រាន់តែឮសំដីទារកទាំងបីនាក់ឆ្លើយប៉ុណ្ណោះ អាចជ្រាបដល់អំបូរសាវតារពូជពង្សទាំងអស់ (សុភាសិតថា សំដីប្រាប់ជាតិ កិរិយាមារយាទប្រាប់ត្រកូល) មានព្រះគាថាព្រះពោធិសត្វពោលថា ៖

អាចារោ កុលមាខ្យាតិ ទេសខ្យាតិ ភាសិតំ
សម្ភមោ បេមមាខ្យាតិ វណ្ណោ បូភ ខ្យាតិ ភោជនំ ។

អធិប្បាយថា កិរិយាមារយាទប្រាប់ត្រកូល, ពាក្យពោលរមែងឲ្យស្គាល់ទីអាង (ជាតិ) សេចក្តីព្រមព្រៀងរមែងឲ្យស្គាល់សេចក្តីស្រឡាញ់រាប់អាន កិរិយាបរិភោគអាហាររមែងឲ្យស្គាល់ពណ៌សម្បុរកាយ ៗ ព្រះបាទធនញ្ជយគោរព្យរាជ ទ្រង់សណ្តាប់ពាក្យនោះ ហើយព្រះអង្គត្រាស់ព្រះគាថាការពារពាក្យនិន្ទាថា ៖

យថាបិ កុលតោ បុប្ផា សេលតោ មណី គណ្ហិយោ
អាជានិយំ កន្ទ្រភិតោ ឃរំ បណ្ឌិតជាតិយោ ៗ

សេចក្តីថា បុគ្គលគប្បីកាន់យកបណ្ឌិតអ្នកប្រាជ្ញ ឲ្យដូចជាបុគ្គលបេះយកផ្កាអំពីត្រួយឈើ ដូចជាកាន់យកកែវមណីអំពីថ្កុំ ទាំងដូចជាបុគ្គលកាន់យកសេះអាជា-នេយ្យអំពីមេលា ក៏យ៉ាងនោះដែរ ៗ ទើបព្រះរាជាទ្រង់ប្រជុំតាំងបំពាក់ស័ក្តិយសឲ្យទារកទាំងបីដូច្នេះ គឺទ្រង់ព្រះរាជទានងារដល់ទេសកណិកាបុត្ត ជាកូនស្រីផ្កាមាសជាសុន្ទរពលយបណ្ឌិត ៗ ឆត្តបត្តកុមារ ជាកូននៃអ្នកល្បែងនោះ ជាឥន្ទ្ររម្មណ-បណ្ឌិត ៗ តិត្តិកុម្មលបុត្តកុមារ ជាកូននៃអ្នកបំបាប់នោះ ជាអភយបណ្ឌិត ៗ ហើយទ្រង់ព្រះរាជទានពលពាហនៈជាច្រើន ទាំងផ្ទះសម្រាប់នៅទាំងបីនាក់ក្នុងទីបំផុតនៃរាជបរិស័ទនៃព្រះធនញ្ជយបណ្ឌិតនោះឯង ៗ តាំងពីគ្រឹមនោះមកបណ្ឌិតទាំងបីនាក់តែងបំរើព្រះរាជា ទាំងធ្វើការបំពេញរាជកិច្ចជាមួយនឹងព្រះពោធិសត្វហៃ ៗ មកដោយសារព្រះធនញ្ជយបណ្ឌិតបំភ្លឺផ្លូវជាដរាប ប៉ុន្តែមានគំនុំគុំព្យាបាទបង់ពៀរនឹងព្រះពោធិសត្វជាប់ដូចជាស្រមោល ព្រោះអ្នកទាំងបីគ្មានបេះវិជ្ជាអ្វីទេ គ្រាន់តែបេះនិយាយស្ទាន ៗ ក៏បានធ្វើធំពៅហួសរៀនវិទ្យាសាស្ត្រ ៗ សូមលោកអ្នកមានប្រាជ្ញពិនិត្យសេចក្តីដែលបានពោលមកនេះ ទោះបីមិនបានសព្វគ្រប់ តែគង់មាន

ឧបាយខ្លះជាគោល ៗ ហើយ ៗ វេលាសំដែងអំពីការជ្រើសរើសរកអ្នកមាន ជម្រេះវិជ្ជានឹងចរិយាឲ្យធ្វើជាអ្នកជំត្រួតត្រាក្នុងប្រទេស សូមបញ្ចប់ប៉ុណ្ណោះ ឯរំ សមគួរនៅវេលា ៗ

( នៅមានត )

ព្រះគ្រូបុរិមវាសី អ៊ូ-ចេវ



បារាយណ៍ថ្ងៃទី ២៥ ខែតុលា ឆ្នាំ ១៩៥៦

ខ្ញុំបាទនាម ហង្ស-អៀង ទីលំនៅៗ ឃុំបារាយណ៍ ខេត្តកំពង់ធំ សូមជំរាបចូលមក លោកចាន់ហ្វាន់បណ្ណាធិការទស្សនាវដ្ដីពុទ្ធិកវិទ្យាល័យវត្តលង្កាសង្កាត់លេខ ៦ ភ្នំពេញ

សូមទានជ្រាប ៗ

ដ្បិតខ្ញុំបាទបានជាវទស្សនាវដ្ដីនេះ មើលអស់ចំនួនជាងមួយឆ្នាំប្លាយមកហើយ ឃើញថាពេញចិត្តជាទីបំផុត ដោយទស្សនាវដ្ដីពុទ្ធិកវិទ្យាល័យនេះ អាចញុំាងមនោគតិរបស់ខ្ញុំបាទឲ្យរឿងរិតតែជ្រះថ្លាៗឡើងក្នុងព្រះពុទ្ធសាសនាតទៅ ដោយឃើញរឿងរ៉ាវនៅប្រទេសឥណ្ឌាអំពីបុរាណវត្ថុ កាលព្រះសម្ពុទ្ធគង់ធម្មានៅ ដែលមានការបាក់បែកអស់ទៅហើយនោះ ឥឡូវនេះមានពុទ្ធជនក្នុងប្រទេសឥណ្ឌាទាំងប៉ុន្មាន ព្រមទាំងប្រទេសដទៃខ្លះៗ បានជួសជុលកបចំស្ដាបនាឡើងវិញ ហាក់ដូចជាព្រះសម្ពុទ្ធគង់ធម្មានៅឡើយ ប៉ុណ្ណោះជាដើមនេះហើយដែលនាំឲ្យដួងវិញ្ញាណរបស់ខ្ញុំបាទ មានលទ្ធផលផ្ដិតជាប់នៅក្នុងពុទ្ធានុស្សតិជានិច្ចគ្រប់វេលាមិនមានភ្លេចត្រង់ណា ។

ប៉ុន្ដែមកមានអាក់អួលឧបសគ្គមិនស្រួលក្នុងចិត្តទៅវិញ អំពីទស្សនាវដ្ដីនេះមិនសូវទៀងទាត់សោះ ព្រោះខ្ញុំបាទបានឮលោកបណ្ណាធិការផ្សាយដំណឹងត្រង់លេខ ៥ ថាក្នុង១ខែចេញមួយគ្រប់ៗ តែខែ ឥឡូវនេះមិនឃើញដូចដំណឹងលោកបណ្ណាធិការផ្សាយបន្ដិចសោះ ខ្ញុំបាទបានទទួលទស្សនាវដ្ដីនេះមានតែមួយខែកន្លះឬ២ខែដែលទទួលញឹកញយជាងគេច្រើនតែ២ខែខ្វះ១ថ្ងៃឬ២ថ្ងៃប៉ុណ្ណោះ ។ ខ្ញុំបាទឆ្ងល់ណាស់ ថប់ក្រែងតែលោកបណ្ណាធិការផ្សាយដំណឹងភាន់ច្រឡំទេដឹង? ឬមួយក៏ពុម្ពច្រឡំទេ? ខ្ញុំបាទថប់ក្រែងតែលោកភាន់ច្រឡំ គឺបំរុងនឹងផ្សាយដំណឹងថា២ខែ១លេខទៅជាច្រឡំដាក់ថា១ខែ១លេខទៅវិញទៅ? នេះបើពិនិត្យទៅតាមដំណើរចេញទស្សនាវដ្ដីរបស់លោក ។

មិនមែនយឺតយូរអំពីដំណើរផ្ញើរទេ គឺខ្ញុំបាទនៅធ្វើការក្នុងសាលាស្រុកបាពយណ៍ តែសព្វថ្ងៃនេះ បើទុកជាដូចម្ដេចក៏មកទាន់ក្នុងរវាង ៣៥ឬ៣៦ ថ្ងៃដែរ ។ ម្យ៉ាងវិញទៀត ខ្ញុំបាទមើលត្រង់ភាគលេខ ៥ ដូចស្ដាប់មិនបានសោះ អំពីឧបាសក-សិកា ទទួល

បរិភោគបង្អាន់ដែលលោកសង្ស័យថាមានទោសនោះ តើមានទោសមែនឬពុំមែនទេ ? ព្រោះលោកបណ្ណាធិការមិនឃើញវិនិច្ឆ័យសេចក្ដីនេះឲ្យស្រឡះទៅតាមសំនួរពុទ្ធជនខែត្រស្ទឹងត្រែងសោះ ព្រោះឧបាសក-សិកា នៅស្រុកខ្ញុំបាទកំពុងតែផ្អើលរឿងទោសកំហុសដែល លោកគ្រូអាចារ្យបានអធិប្បាយខ្លាំងណាស់ ។ បើខ្ញុំបាទយល់តាមលោកគ្រូអាចារ្យបានអធិប្បាយក្នុងទស្សនាវដ្ដីលេខ ៥ មែន ខ្ញុំបាទសូមថាទាំងបព្វជិតទាំងគ្រហស្ថបានរួចខ្លួនតិចណាទេ ព្រោះក្នុងវត្តមួយៗ ក្នុងកុដិ១ អង្គ បើយ៉ាងហោចណាស់ ក៏មានក្មេង១ឬ២ រូបដែរ បើលោកគ្រូសង្ស័យពជវិញលែងរួចសោះតែម្ដងហើយ ។

ក្នុងក្រុងក្ដីក្រៅក្រុងក្ដីដូចគ្នាទាំងអស់ ។

ហេតុនេះ សូមលោកបណ្ណាធិការពិនិត្យមើលទស្សនាវដ្ដីលេខ៥, ហើយវិនិច្ឆ័យឲ្យច្បាស់លាស់ឲ្យបានផង ព្រោះនៅទីក្រុងសម្បូណ៌លោកអ្នកប្រាជ្ញធំៗច្រើន នឹងបានញុំាងបញ្ហាទាំងនេះឲ្យច្បាស់មិនខាន ។

នៅទីបំផុតនេះខ្ញុំបាទសូមប្រសិទ្ធិពរចំពោះទស្សនាវដ្ដីពុទ្ធិកវិទ្យាល័យ ឲ្យលូតលាស់ស្ថិតនៅជាស្ពានអាចញុំាងពុទ្ធជនអ្នកអានទាំងឡាយ ក្នុងកម្ពុជរដ្ឋទាំងមូលឲ្យមានអារ្យធម៌ នឹងរស្ម៊ីដុំរុងរឿងសមហានៈជាពលរដ្ឋឯករាជតទៅ ។ ហើយខ្ញុំបាទសូមអភ័យទោសអំពីលោកបណ្ណាធិការថា ក្រែងខ្ញុំបាទសរសេរមកនេះមានបើលើសល្ហួសត្រង់ណាទ្គាំធ្គង់សុំអនុញ្ញាតឲ្យបាន នឹងសូមលោកបណ្ណាធិការទទួលសេចក្ដីគប់អានដ៏-ជ្រាលជ្រៅអំពីខ្ញុំបាទដោយសុទ្ធចិត្តកុំបីខាន ។

ហត្ថលេខា

ហង្ស-អឿន

កម្ពុជាក្រោមថ្ងៃ២កក្កដា ព.ស. ២៤៩៩ គ.ស. ១៩៥៥

ស្លាបប៉ាកការបស់អាត្មារនែគាំង ពុំដែលបង្ហូរទឹកទៅលើទំព័រទស្សនាវដ្ដីណាមួយទេ ។ ដោយបានខ្ចីទស្សនាវដ្ដីពុទ្ធិកវិទ្យាល័យ លេខ៥ ឆ្នាំ៥៦ អំពីព្រះថេរមួយរូប (ព្រោះភាពជាអ្នកក្រ) លុះបានអានទៅ ឃើញមានពាក្យសួរនិងពាក្យឆ្លើយ ចំពោះពុទ្ធជនដែលបរិភោគភោជនាហារអំពីព្រះសង្ឃ តែឆ្លើយពុំទាន់ជាប់ស្រេច ក៏អំពាវនាវឲ្យគេជួយដោះស្រាយទៀត ព្រមទាំងលោកបណ្ណាធិការ ក៏ស្រែកឲ្យគេជួយដោះស្រាយដែរ ។ ក្នុងករណីនេះ, ស្លាបប៉ាកការអាត្មា បានត្រីបង្ហូរទឹក វិនិច្ឆ័យបញ្ហាដ៏ចង្អៀតនុ៎ះ ទៅលើទំព័រទស្សនាវដ្ដីនេះ ល្បងមើលម្ដងជាលើកដំបូង ដូចតទៅ:

បរិភោគ៤ប្រការ ព្រះពុទ្ធទ្រង់អនុញ្ញាតឲ្យតែពួកភិក្ខុពិតមែន, តែដូចយ៉ាងអនាមដ្ឋបិណ្ឌបាត (បង្ហាន់ចំស្រឡាង) ដែលភិក្ខុស្វែងរកបានមកហើយ ទ្រង់អនុញ្ញាតឲ្យភិក្ខុចែករំលែកដល់មាតាបិតាជាដើម(បុះបើមាតាបិតាសមាទានសីលដែរមិនមែនជាឧបាសកឧបាសិកាឬ ? ) មិនចាំបាច់និយាយដល់វត្ថុសេសសល់ ។ ឯវត្ថុសេសសល់ ចំពោះភោជនាហារ ភិក្ខុឈប់ត្រូវការទៀតហើយ ឈ្មោះថាផុតព្រំដែនបច្ចវេក្ខណៈហើយ មានពុទ្ធប្បញ្ញត្តិហាមមិនឲ្យភិក្ខុឲ្យដល់ចោរ, ដល់បុរសប្រាថ្នារាជសម្បត្តិ ព្រោះអ្នកទាំងនោះកាលបើបានវត្ថុសំណល់ មុខជាខឹងហើយប្រាថ្នាធ្វើសេចក្ដីអន្តរាយដល់ជីវិតនៃភិក្ខុផង ដល់សាសនាផង ទ្រង់អនុញ្ញាតឲ្យភិក្ខុឲ្យអនាមដ្ឋបិណ្ឌបាត, ពួកជនដទៃក្រៅពីចោរនិងបុរសកៀសខ្លួនដោយប្រាថ្នារាជ្យនោះ ឥតមានពុទ្ធប្បញ្ញត្តិ ឬពុទ្ធានុញ្ញាតថា “ភិក្ខុមិនគួរឬ គួរឲ្យដល់គ្រហស្ថ, គ្រហស្ថមិនគួរ ឬគួរបរិភោគ” ដូច្នេះឡើយ ។ បទណាដែលរួចផុតចាកពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាតហើយ ត្រូវអ្នកប្រទេសនិយមប្រើ, បទនោះ

ពុទ្ធសាសនិកជនគប្បីជ្រាបថា ប្រតិបត្តិទៅហើយ មិនមានទោសពៃរ៍អ្វីឡើយ ។

ត្រង់បទថា «សង្ឃកប្បិយការកៈអ្នកស៊ីវត្តដែលសម្រេចដល់សង្ឃ» ថាមានទោស មិនបានជួបនឹងព្រះសិក្ខាបទមេត្រីនោះ គឺលោកសំដៅបុគ្គលលួចលាក់របស់សង្ឃ យកទៅបរិភោគ, មិនមែនសំដៅអ្នកបរិភោគរបស់ដែលសង្ឃបានអនុញ្ញាតហើយនោះទេ ។

ចំណែកខាងភិក្ខុ ឲ្យវត្ថុដល់គ្រហស្ថ មានទោសនឹងមិនមានទោសនោះគប្បីជ្រាបនូវអំពើពីរប្រការ ដែលមានលំនាំអាការៈនៃភិក្ខុប្រហាក់ប្រហែលគ្នា តែវត្ថុបំណងនៃភិក្ខុខុសគ្នា ។ ឯអំពើពីរប្រការនុ៎ះគឺ អនេសន ១ នឹងបដិសណ្ឋារៈ ១ ។

អនេសនៈ ការស្វែងរកបច្ច័យខុសទំនង បានដល់ភិក្ខុមានសេចក្ដីលោភលន់ កាលបើជួបនឹងគ្រហស្ថ ឬគ្រហស្ថទៅកាន់សំណាក់ខ្លួនហើយ ក៏និយាយរួសរាយរាក់ទាក់ចាក់បេកចាក់ស្រែផង ឲ្យនៅវត្ថុនេះនោះខ្លះផង ដោយចិត្តប្រាថ្នាថាធ្វើជាធ្លាក់ឬជានុយដើម្បីទាក់ឬស្ទូចយកលាភច្រើនអំពីគ្រហស្ថមកវិញ ដូចជាបាលីថា «លាភេន លាភំ និជិគឹសនតា ការស្វែងរកលាភ ដោយការឲ្យលាភ គឺថាឲ្យលាភទាក់យកលាភ» ។ ភិក្ខុរាក់ទាក់ឬឲ្យវត្ថុក្នុងបទអនេសនៈនេះមានទោស ព្រះសម្ពុទ្ធទ្រង់ហាមប្រាម ។

បដិសណ្ឋារៈ ការស្រុះស្រួលទទួលរាក់ទាក់មានពីរប្រការគឺ ធម្មប្បដិសណ្ឋារៈ ១ នឹងអាមិសប្បដិសណ្ឋារៈ ១ ។ ក្នុងទីនេះ, លើកទុកនូវធម្មប្បដិសណ្ឋារៈ, នឹងនិយាយតែអាមិសប្បដិសណ្ឋារៈដោយសង្ខិតន័យ តាមអដ្ឋកថា គេសង្គ្រោះវត្ត ក្នុងតតិយបារាជិកដូចនេះ

អាគន្តុកជន (ជនអ្នកមកដល់) ក្ដី, ទលិទ្ទជន (ជនអ្នកទ័លក្រ) ក្ដី, ឥស្សរជន (ជនមានបណ្ដាសក្ដិធំ) ក្ដី, បរជន (ជនដទៃ) ឯណាទីមួយក្ដី កាលបើមកដល់វត្តហើយ

ក្នុងកាលគួរ (ពីព្រឹកដល់ថ្ងៃត្រង់) ភិក្ខុគប្បីធ្វើអាមិសបដិសណ្ឋារៈ គឺឲ្យបបរនឹងភត្ត, ក្នុងវិកាល (ថ្ងៃជ្រេពីត្រង់ទៅ) បើមានអង្ករ គប្បីឲ្យ, សយនដ្ឋាន (កន្លែងសម្រាប់ដេក) គប្បីឲ្យ ។ តែភិក្ខុមិនត្រូវញ៉ាំងលោភចិត្ត ចង់បានលាភពីជននោះវិញទេ សមដូចជាបាលីថា "មនុស្សា នាម បតុប្បច្ចយ.ទាយកា ឯវំ សង្គហេ ករិយមានេ, បុនប្បុនំ បសីទិត្វា ឧបការំ ករិស្សន្តីតិ បិត្តំ ន ឧប្បាទេតព្វំ = ភិក្ខុពុំគួរញ៉ាំងចិត្តឲ្យកើតឡើងថា "ធម្មតាមនុស្សទាំងឡាយ កាលបើត្រូវអាត្មាអញធ្វើសេចក្ដីសង្គ្រោះយ៉ាងនេះ មុខជានឹងជ្រះថ្លាហើយធ្វើឧបការៈរឿយ ៗ " ។ ប្រសិនណាបើភិក្ខុ ញ៉ាំងលោភចិត្តឲ្យកើតឡើងយ៉ាងនេះបាត់ជាបទអនេសនៈ ។ តែនេះមិនដូច្នោះ គឺភិក្ខុទទួលពក់ទាក់ដោយអាមិស ប្រកបដោយសង្គហចិត្តតែម្យ៉ាងយ៉ាងនេះហៅថា អាមិសបដិសណ្ឋារៈ ឥតមានអាបត្តិអាប៉ែងអីទេ ព្រះសម្ពុទ្ធទ្រង់អនុញ្ញាត ។

ស្តាប់ប៉ុ៎កកាអាត្មាភាព សូមលាសិនហើយ
តែះបើហៅរកទៀត នឹងមកឲ្យជួបទៀត ។

ចាកដែនកម្ពុជាក្រោម

ភិ.ន.-ណ.

---

# ការប្រែប្រួល

កាលពីដើមនៅក្នុងជម្ពូទ្វីបមានកុដុម្ពិកចាស់ម្នាក់ មានកូនប្រុសសំឡាញ់ម្នាក់នឹងសេះញីមួយ ។ មានមួយថ្ងៃស្រាប់តែសេះញីនោះដើរទៅបាត់ ។ ជនជិតខាងមកថែកសោកសញ្ញានឹងតានោះ ។ តានោះនិយាយថា: "បាត់សេះ, ហេតុ

ដូចម្ដេចក៏អ្នកទាំងឡាយដឹងថា នេះជាជោគវាសនាអាក្រក់របស់ខ្ញុំ ? ”

មិនបានប៉ុន្មានថ្ងៃសេះញីនោះត្រឡប់មកវិញ នាំទាំងសេះអាជានេយ្យមួយមកផង ។ ជនជិតខាងក៏មកអបអរសាទរសរសើរជោគល្អ ។ តាកុដុម្ពិកនិយាយថា : “ បានសេះប្រសើរតែពូកែ ម្ដេចក៏អ្នកទាំងឡាយដឹងថានោះជាជោគលាភដ៏ល្អរបស់ខ្ញុំ ? ”

តាំងអំពីថ្ងៃបានសេះល្អមក កូនកំលោះរបស់គាត់ជិះបំបោលប្រណាំងលេងចុះឡើងគ្មានឈប់ឈរ ទាល់តែធ្លាក់បាក់ជើង ។ ជនជិតខាងមកត្អូញត្អែរលួងលោមរំលែកទុក្ខអកតញ្ញូ ។ កុដុម្ពិកនិយាយថា : “ កូនប្រុសរបស់ខ្ញុំបាក់ជើងម្ខាង ហេតុដូចម្ដេចក៏អ្នកទាំងឡាយដឹងថានេះជាសំណាងអាក្រក់របស់ខ្ញុំ ? ”

ឆ្នាំជាបន្ទាប់មក សង្គ្រាមកលិយុគកើតឡើងទូទៅទាំងជម្ពូទ្វីប ។ កូនកំលោះជនជិតខាងទាំងប៉ុន្មាន ត្រូវរកការជម្រើសឲ្យធ្វើទាហានយោធាទាំងអស់គ្នា ។ យុវ-ពលទាំងនោះទៅច្បាំងតយុទ្ធនឹងសត្រូវស្លាប់ទាំងអស់គ្មានសល់ដល់ម្នាក់ឡើយ ។ កូនកំលោះរបស់លោកតាកុដុម្ពិកចាស់ ព្រោះតែបាក់ជើងពិកលពិការទៅណាមិនរួចក៏បានរស់រានមានជីវិតនៅបំរើបិតាជាដែលជាអ្នកញញឹមប្រិមប្រិយ កាលពេលដែលជនជិតខាងមកសាកសួរអំពីជោគមិនល្អនិងជោគល្អ ។ នេះគឺការប្រែប្រួលរបស់លោក !

សូមព្រះតេជព្រះគុណជាបុព្វការី មេត្តាខន្តីអភ័យទោសពិនិត្យកែរឿងប្រែប្រួលនេះហើយមេត្តាបោះពុម្ពទស្សនាវដ្ដីមិត្តសាលាបាលី

ដោយសគ្គហាទិធម៌ និងព្រហ្មវិហារធម៌ ។

To : His Excellence President of Mittasalapali's Association,
Phnom-Penh Cambodia
From : Bhikkhu Va-Yav ( Ghosanando ) Nalanda Pali Instituts
Patna India

# សេចក្ដីថ្លែងអំពីការអប់រំសីលធម៌នៅក្រោមមហាកុដិវត្តឧណ្ណាលោម

សួស្ដីកល្យាណមិត្រ !

ខ្ញុំ, ក្នុងនាមនៃគណៈកម្មការសីលធម៌, សូមសំដែងមនោសញ្ចេតនាប្រកបដោយសោមនស្សស្មោះសរយ៉ាងអស្ចារ្យ ចំពោះអស់លោកទាំងឡាយ ដែលបានចូលមករួមប្រជុំអប់រំសីលធម៌ ក្នុងវេលារាត្រីថ្ងៃសៅរ៍នេះ ។

ការអប់រំសីលធម៌ ដែលយើងបានធ្វើមករាល់តែថ្ងៃសៅរ៍និងថ្ងៃពុធរវាង៥ ខែមកហើយ ឃើញថាបានលទ្ធផលយ៉ាងក្រាស់ក្រែល ដោយមិត្តជាសិស្សសីលធម៌ទាំងឡាយ បានចេះចាំនូវធម៌សម្រាប់សូត្រថ្វាយបង្គំព្រះរតនត្រ័យ, ក្នុងធម៌និងការបណ្ដុះនិស្ស័យអប់រំសីលធម៌ (គឺការទំហឹកហាត់គំនិតមារយាទឲ្យមានសេចក្ដីថ្លៃថ្នូរ, រក្សាវិន័យ, បំពេញការសិក្សាផ្លូវលោកនិងផ្លូវធម៌) កាន់តែចំរើនកើនទៅមុខហើយ ។ ធនុះជំខាប់ខ្ទននិងការប្រជុំដ៏ទៀងទាត់របស់យើងនេះ អាចញ៉ាំងវឌ្ឍនធម៌ទាំងពីរផ្នែកគឺ: សាសនវឌ្ឍនធម៌និងលោកិយវឌ្ឍនធម៌ ឲ្យរីកទៅកាន់ទីដៅមួយ ដែលយើងជាអ្នកកាន់ព្រះពុទ្ធសាសនា បានប៉ងប្រាថ្នាមកយូរហើយ ។ វឌ្ឍនធម៌នោះមានពីរប្រភេទគឺ: សាសនវឌ្ឍនធម៌ (សេចក្ដីចំរើនខាងផ្នែកសាសនា) ១, លោកិយវឌ្ឍនធម៌ (សេចក្ដីចំរើនខាងផ្នែកផ្លូវលោក) ១ ។ សាសនវឌ្ឍនធម៌មាន៣យ៉ាងគឺ:

១– បរិយត្តិវឌ្ឍនធម៌– សេចក្ដីចំរើននៃការរៀនសូត្រធម៌វិន័យ ។

២– បដិបត្តិវឌ្ឍនធម៌– សេចក្ដីចំរើននៃសេចក្ដីប្រតិបត្តិ ។

៣– បដិវេធវឌ្ឍនធម៌– សេចក្ដីចំរើននៃការត្រាស់ដឹង ។

# (ពាក្យកំណាព្យភាពខ្មែរសម័យ)

សូមជូនមកលោកក្រុមអ្នកនិពន្ធទស្សនាវដ្តីជាអនុស្សាវរីយ៍

នៅទីប្រជុំភូមិទីឃុំ ប្រមូលចង្កុំរួមជាស្រុក
អ្នកស្រែចំការពុំសូវសុខ មានផុកលើកជូនក្នុងខ្លួនច្រើន ៗ
សព្វថ្ងៃខ្មែរខ្លះធ្វើស្រែបាន មានចិត្តអាក់ទឹងរាជការ
ទឹកទំនាស់ចិត្តក្នុងចិន្តារ ដោយថារាជការចេញថ្ងៃថោក
បំណែកអ្នកស្រែលំបាកក្រ ដេកចាំអង្ករខ្មែរមានដោក
ឲ្យតែរាជការឲ្យថ្លៃថោក ស្រួលទិញបរិភោគទៅថ្ងៃក្រោយ
នៅក្នុងសម័យពេលថ្ងៃមុន អ្នកក្រដាបដុនពេកណាស់កើយ
រកទិញអង្ករពុំបានឡើយ ម្ល៉ោះហើយខំប្រឹងចរយាត្រា
ទទួលគាប់ជួនទឹងអ្នកលក់ អង្ករអន្ទក់នៅក្រៅផ្សារ
ក៏បានដើរចូលទៅតវ៉ារ សួរថាអង្ករនេះថ្លៃប៉ុន្មាន ៗ
អ្នកលក់ភ្ញាក់ខ្លួនមើលប្រញាប់ ដោយស្មានក្នុងចិត្តថាទាហ៊ាន
លុះមើលឃើញជាក់គាត់ថ្លៃភ្លាម មិនឲ្យទឹមតាមនៅយូរការ ៗ
អង្ករខ្ញុំលក់ខ្លះបំរ៉ម ថ្លៃកៅសិបប្រាំតាមត្រូវការ
ឥតមានសុំថ្លៃបានឡើយណា ត្រូវការប៉ុន្មានខ្ញុំរាល់ឲ្យ ៗ
អ្នកទិញឆ្លើយតបជាប្រញាប់ ឲ្យរាជការចាប់ឥឡូវហើយ
អ្នកលក់ឆ្លើយថានែអ្នកអើយ កុំយល់ដូច្នោះគឺខុសទេ ៗ
ឥវ៉ាណទំនិញចិនពេញផ្ទះ ម្តេចមិនដាក់ថ្លៃដោយហូរហែរ
ហេតុអ្វីដាក់ថ្លៃអង្ករខ្មែរ ត្រង់ចិនខុសសែហ៍មិនដាក់ផង ៗ

រោងពុម្ពទីរីយ

នៅខាងត្បូងផ្សារអូរឫស្សីសង្កាត់លេខ៥